# ក្រសួងអប់រំ យុវជន និងកីឡា
MINISTRY OF EDUCATION YOUTH AND SPORTS

# សាកលវិទ្យាល័យវ៉ាន់ដា
VANDA UNIVERSITY

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ការរីកចម្រើននៃវិស័យហិរញ្ញវត្ថុនៅកម្ពុជា
THE DEVELOPMENT OF FINANCIAL SECTOR IN CAMBODIA

## ជំនាញ ហិរញ្ញវត្ថុ និងធនាគារ

រាជធានីភ្នំពេញ-ឆ្នាំ២០២៥

PHNOM PENH-2025

ក្រសួងអប់រំ យុវជន និងកីឡា
MINISTRY OF EDUCATION YOUTH AND SPORTS
សាកលវិទ្យាល័យវ៉ាន់ដា
VANDA UNIVERSITY

# សារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ

# ការរីកចម្រើននៃវិស័យហិរញ្ញវត្ថុនៅកម្ពុជា
# THE DEVELOPMENT OF FINANCIAL SECTOR IN CAMBODIA

គ្រូណែនាំ៖ ត្រុង សាវរី

ជំនាញ ហិរញ្ញវត្ថុ និងធនាគារ

រាជធានីភ្នំពេញ-ឆ្នាំ២០២៥
PHNOM PENH-2025

**គណៈកម្មការត្រួតពិនិត្យសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជំនាន់ទី២២**
**ប្រធានបទ៖ ការរីកចម្រើនវិស័យហិរញ្ញវត្ថុនៅកម្ពុជា**

គណៈកម្មការវាយតម្លៃទី១

បេក្ខបណ្ឌិត មាស សំណាង

គ្រូណែនាំ

គ្រុង សាវរី

គណៈកម្មការវាយតម្លៃទី៣

បេក្ខបណ្ឌិត យ៉ែម សុខហៀក

គណៈកម្មការវាយតម្លៃទី២

បេក្ខបណ្ឌិត យ៉ាក វុទ្ធី

ប្រធានគណៈកម្មការវាយតម្លៃ និងជានាយក
មជ្ឈមណ្ឌលស្រាវជ្រាវ

បណ្ឌិត សេង សំអឿន

អនុប្រធានគណៈកម្មការវាយតម្លៃ និងជានាយករង
មជ្ឈមណ្ឌលស្រាវជ្រាវ

បេក្ខបណ្ឌិត ស្រេង ផល្លា

**សាកលវិទ្យាធិការ**

**បណ្ឌិត ហេង វ៉ាន់ដា**

សាកលវិទ្យាធិការរងអចិន្ត្រៃយ៍

បណ្ឌិត ហ៊ូ គុជគន្ធលីនណា

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រជំនាញធនាគារនិងហិរញ្ញវត្ថុនៅសាកលវិទ្យាល័យវ៉ាន់ដាអស់រយៈពេល៤ឆ្នាំសិក្សារួចមក ក្រុមយើងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើនដែលពាក់ព័ន្ធ នឹងមុខវិជ្ជាធនាគារនិងហិរញ្ញវត្ថុ ជាពិសេសក្រុមយើងខ្ញុំបានយល់ច្បាស់ថាជំនាញធនាគារនិងហិរញ្ញវត្ថុ គឺជាជំនាញមួយមានសារៈសំខាន់មួយដែរសម្រាប់ទីផ្សារបច្ចុប្បន្ន ក្នុងនោះស្ថាប័នរដ្ឋក្តី ឯកជនក្តី ឬអង្គការក្រៅរដ្ឋាភិបាលក្តីសុទ្ធតែត្រូវអនុវត្តកិច្ចការហិរញ្ញវត្ថុនិងធនាគារដូចគ្នា។ ដោយឡែកដើម្បីឱ្យការសិក្សារបស់និស្សិតកាន់តែមានគុណភាពខ្ពស់សាកលវិទ្យាល័យវ៉ាន់ដា បានបញ្ចូលនូវមុខជំនាញសំខាន់ៗដែលពាក់ព័ន្ធ នឹងការងារធនាគារនិងហិរញ្ញវត្ថុ តាមកម្មវិធីសិក្សាក្នុងឆ្នាំសិក្សាទីមួយ រហូតដល់ឆ្នាំសិក្សាទី៤។

គ្រប់មុខវិជ្ជាទាំងអស់ សុទ្ធតែមានសារៈសំខាន់ក្នុងការត្រួសត្រាយផ្លូវនិស្សិតឱ្យយល់ច្បាស់ពីការអនុវត្តការងារធនាគារ ពីការចាប់ផ្តើមរៀបចំផែនការការអនុវត្តការបញ្ចប់ និងត្រួតពិនិត្យវាយតម្លៃព្រមទាំងផ្តល់ជាអនុសាសន៍នៅក្នុងការងារធនាគារ ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រងនៅក្នុងស្ថាប័នខ្លួន ក្នុងន័យឆ្លើយតបឱ្យបានល្អប្រសើរនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលបានដាក់ចេញ។ ដោយក្រុមយើងខ្ញុំសង្កេតឃើញថាកិច្ចការងារមួយនេះ មានសារៈសំខាន់ខ្លាំងស្របពេលនៃការសរសេរសារណាបញ្ចប់ ការសិក្សាថ្នាក់បរិញ្ញាបត្របានមកដល់ទើបក្រុមយើងខ្ញុំសម្រេចចិត្តជ្រើសរើសនូវប្រធានបទមួយស្តីពី **"ការរីកចម្រើននៃវិស័យហិរញ្ញវត្ថុនៅកម្ពុជា"** យកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងក្នុងគោលបំណងឱ្យអ្នកស្រាវជ្រាវទាំងអស់ ឱ្យបានយល់កាន់តែស៊ីជម្រៅពីការរៀបចំសារណា។ ក្រុមយើងខ្ញុំសង្ឃឹមថា ការរៀបចំសារណានេះនឹងបានចូលរួមចំណែក ក្នុងការស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗ ព្រមទាំងអ្នកស្រាវជ្រាវដ៏ទៃទៀតដែលមានបំណងសិក្សាស្វែងយល់ពីកិច្ចការនេះ។

ជាទីបញ្ចប់ក្រុមយើងខ្ញុំ សូមមេត្តាខន្តី អភ័យទោសពីសំណាក់ លោកគ្រូអ្នកគ្រូ រៀមច្បង និងអ្នកអានទាំងអស់នូវរាល់កំហុសឆ្គងដែលកើតមាន ដោយអចេតនានៅក្នុងសារណានេះក្រុមយើងខ្ញុំរីករាយនឹងទទួលយករាល់ការរិះគន់ក្នុងន័យស្ថាបនា ដើម្បីឱ្យការរៀបចំលើកក្រោយទៀតមានភាពកាន់តែល្អប្រសើរ។

# រចនាសម្ព័ន្ធ



រិទ្ធ ស្រីដែន
B22/1692



ឡៀប សុវណ្ណរតនា
B22/792



សុខ ស្រីសរ
B22/1064



ហ៊ិន ឧត្តម
B22/235



ជ័យ កក្កដា
B22/2210

# សេចក្តីថ្លែងអំណរគុណ

ក្រុមយើងខ្ញុំជានិស្សិតនៃ សាកលវិទ្យាល័យវ៉ាន់ដា ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២២ ជំនាញហិរញ្ញវត្ថុនិងធនាគារ

**សូមសំដែងនូវការគោរពដឹងគុណ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ**

ក្រុមគ្រួសារដែលបានជួយឧបត្ថម្ភ គាំទ្រ ទាំងសម្ភារៈ ថវិកា និងស្មារតី ជំរុញលើកទឹកចិត្ត ដល់ក្រុមយើងខ្ញុំ ក្នុងការសិក្សារៀនសូត្រដើម្បីទទួលបានចំណេះដឹងរហូតមកដល់សព្វថ្ងៃនេះ។ ក្នុងនោះក្រុមយើងខ្ញុំសូមសំដែងនូវការគោរព និងកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុត ដល់អ្នកមានគុណ ដែលបានផ្តល់កំណើតដល់យើងខ្ញុំ គ្រប់រូប និងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់បណ្ឌាសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ ទាំងអស់ ដែលបានបណ្តុះបណ្តាលក្រុមយើងខ្ញុំនាពេលកន្លងមក។

ក្រុមយើងខ្ញុំ សូមសំដែងនូវការគោរពដឹងគុណ ដ៏ជ្រាលជ្រៅដល់ឯកឧត្តមបណ្ឌិត **ហេង វ៉ាន់ដា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យវ៉ាន់ដា ដែលបានផ្តល់ទីកន្លែងបណ្តុះបណ្តាលព្រមទាំងផ្តល់បទពិសោធន៍យ៉ាងច្រើនដល់យើងខ្ញុំ។

សូមគោរពថ្លែងអំណរគុណចំពោះអ្នកគ្រូ **គ្រុង សាវទី** ជាគ្រូណែនាំ ដោយបានជួយជ្រោមជ្រែងបង្ហាត់បង្ហាញសព្វបែបយ៉ាង ដើម្បីជួយដល់ក្រុមយើងខ្ញុំបញ្ចប់កិច្ចការសារណានេះជាស្ថាពរ។

សូមគោរពថ្លែងអំណរគុណដល់សាស្ត្រាចារ្យ និងបុគ្គលិកនៃសាកលវិទ្យាល័យវ៉ាន់ដា ទាំងអស់ដែលបានខិតខំប្រឹងប្រែងក្នុងការបង្ហាត់បង្ហាញ លើកទឹកចិត្ត អនុគ្រោះដល់ក្រុមយើងខ្ញុំ រហូតធ្វើឱ្យការសិក្សាបានបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទនៈ។

ឆ្លៀតក្នុងឱកាសនេះដែរ ក្រុមយើងខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់បុគ្គលទាំងអស់ខាងលើឱ្យជួបតែពុទ្ធពរបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អំណះអំណាង

ក្រុមយើងខ្ញុំជានិស្សិតបរិញ្ញាបត្រជំនាញហិរញ្ញវត្ថុនិងធនាគារនៃសាកលវិទ្យាល័យវ៉ាន់ដាជំនាន់ទី ២២៖ សូមធានាអះអាងថា ខ្លឹមសារសារណាក្រោមប្រធានបទ “**ការរីកចម្រើននៃវិស័យហិរញ្ញវត្ថុនៅកម្ពុជា**” នេះគឺជាស្នាដៃរបស់ក្រុមយើងខ្ញុំ ដោយគ្មានការពាក់ព័ន្ធនឹងរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ទិន្នន័យ និងលទ្ធផលនៃការស្រាវជ្រាវដែលលើកឡើងនេះ ជាអត្ថបទស្រាវជ្រាវថ្មីសុទ្ធសាធដែលពុំធ្លាប់មានជនណាម្នាក់យកទៅប្រើប្រាស់ក្នុងការស្រាវជ្រាវពីមុនឡើយ។

ថ្ងៃពុធ ៨កើត ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២៥

**ហត្ថលេខាតំណាងក្រុម**



រិទ្ធ ស្រីដែន

# សេចក្តីសង្ខេបនៃការស្រាវជ្រាវ

សារណា ជាចំណែកមួយនៃកម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រ នៅសាកលវិទ្យាល័យវ៉ាន់ដាគណនេយ្យ ដែលចាំបាច់ដែល តម្រូវឱ្យនិស្សិតបំពេញឱ្យបានជោគជ័យមុននឹងទទួលសញ្ញាបត្រ ដែលបានសិក្សារយៈពេលពីរឆ្នាំជាងកន្លងមកនេះ ទោះយ៉ាងនេះផងដែរក្រុមយើងខ្ញុំក៏ជានិស្សិតទទួល បានការបណ្តុះបណ្តាល និងមានការជ្រោមជ្រែងយ៉ាងកក់ក្តៅ គឺលោកគ្រូអ្នកគ្រូសាស្ត្រាចារ្យដែលបានប្រមូលផ្តុំ នូវចំណេះដឹងគ្រប់បែបយ៉ាងផ្តល់មកអោយយើងទាំងអស់គ្នានៅ ក្នុងគោលបំណងមួយយ៉ាងសំខាន់ គឺការរៀបរៀងនូវប្រធានបទមួយស្តីអំពី "ការរីកចម្រើនវិស័យហិរញ្ញវត្ថុនៅកម្ពុជា"។ ការសិក្សាស្រាវជ្រាវនេះ ក្រុមយើងខ្ញុំមានគោលបំណងស្វែងយល់យ៉ាងលម្អិតទៅលើ ដំណើរនៃការរីកចម្រើនទៅលើវិស័យហិរញ្ញវត្ថុ ដោយបានលើកយកចំណុចមួយចំនួនរួមមាន ស្ថានភាពទូទៅនៃការរីកចម្រើនវិស័យហិរញ្ញវត្ថុនៅកម្ពុជា ប្រភេទនៃវិស័យហិរញ្ញវត្ថុ គោលការណ៍របស់រដ្ឋាភិបាលក្នុងការជួយលើកស្ទួយវិស័យហិរញ្ញវត្ថុ និងការរីកចម្រើនវិស័យហិរញ្ញវត្ថុចំពោះសេដ្ឋកិច្ចកម្ពុជា។

ជាក់ស្តែងបន្ទាប់ពីបានធ្វើការសិក្សារស្រាវជ្រាវទៅលើប្រធានបទរួចមក ធ្វើឱ្យយើងខ្ញុំឱ្យបានយល់និងឃើញនូវភាពជាក់ស្តែង ក្នុងការរីកចម្រើនលើកវិស័យហិរញ្ញវត្ថុពិតប្រាដកមែន ដែលរួមបញ្ចូលជាមួយវិស័យមួយចំនួនដូចខាងលើ ហើយវាមានការទាក់ទងនិងធ្វើឱ្យមានការផ្លាស់ប្តូរក្នុងបរិបទបច្ចេកវិទ្យា សេដ្ឋកិច្ច និងសង្គម។ ដើម្បីជម្រុញឱ្យការរីកចម្រើនផ្នែកវិស័យហិរញ្ញវត្ថុកាន់តែមានភាពលិចឆ្លោ ហើយនិងកាន់តែមានប្រសិទ្ធភាពយើងគួរតែមានការពង្រឹងទៅលើផ្នែកមួយចំនួនដូចជាអភិវឌ្ឍវិស័យធនាគារនិងស្ថាប័នឥណទាន អភិវឌ្ឍទីផ្សារហិរញ្ញវត្ថុក្នុងស្រុក ជួយលើកកម្ពស់សេវាហិរញ្ញវត្ថុឌីជីថលបច្ចេកវិទ្យាឌីជីថលជំរុញការវិនិយោគ ព្រមទាំងគាំទ្រការចូលរួមរបស់វិស័យឯកជន ការស្រាវជ្រាវនេះបានបង្ហាញយ៉ាងច្បាស់ថា វិស័យហិរញ្ញវត្ថុនៅកម្ពុជា រីកចម្រើនយ៉ាងឆាប់រហ័សក្នុងអំឡុងពេល២០២៤ បើទោះបីជាប្រឈមជាមួយស្ថានភាពសេដ្ឋកិច្ចពិភពលោកក៏ដោយ។ ដំណើរការរីកចម្រើននេះ បានជះឥទ្ធិពលយ៉ាងខ្លាំងទៅលើសេដ្ឋកិច្ចជាតិតាមរយៈការគាំទ្រប្រព័ន្ធហិរញ្ញវត្ថុឌីជីថល ការកើនឡើងនៃស្ថាប័នហិរញ្ញវត្ថុឯកជន ការចូលរួមរបស់ FinTech និងការគាំទ្រដោយរដ្ឋតាមរយៈគោលនយោបាយ និងច្បាប់នានា សេវាហិរញ្ញវត្ថុបានកាន់តែមានភាពទូលំទូលាយ រហ័សសុវត្ថិភាព និងងាយស្រួលសម្រាប់ប្រជាពលរដ្ឋជាពិសេសនៅតំបន់ជនបទ។ វិស័យនេះ ក៏បានចូលរួមជួយលើកស្ទួយសេដ្ឋកិច្ចជាតិ ដោយជម្រុញការវិនិយោគការបង្កើតការងារ និងការបង្កើតឱកាសសម្រាប់វិស័យឯកជន។

សរុបសេចក្តីមក ការអនុវត្តគោលការណ៍ដូចដែលបានរៀបរាប់ខាងលើ ពិតជាបានជួយលោកស្ទួយការរីកចម្រើនវិស័យហិរញ្ញវត្ថុនៅកម្ពុជាឱ្យឈានមួយកម្រិត ហើយទាំងជួយពង្រឹងវិស័យនេះតាមរយៈ ការអភិវឌ្ឍស្ថាប័នហិរញ្ញវត្ថុ ការលើកកម្ពស់សេវាឌីជីថល ការជម្រុញវិស័យឯកជន និងការរួមចំណែករបស់ភាគីទាំងមូល ការកែលម្អប្រព័ន្ធច្បាប់និងការគ្រប់គ្រង ទាំងនេះគឺជាមូលដ្ឋានសំខាន់មួយសម្រាប់ការរីកចម្រើនសេដ្ឋកិច្ច ប្រសិនបើមានការគាំទ្រយ៉ាងសកម្ម ក៏អាចនាំឱ្យកម្ពុជាអភិវឌ្ឍទៅកាន់ប្រទេសមានចំណូលមធ្យមខ្ពស់នៅពេលអនាគត។

# មាតិកា

ទំព័រ

អារម្ភកថា ................................................................ i
របនាសម្ព័ន្ធ................................................................ ii
សេចក្តីថ្លែងអំណរគុណ ................................................................ iii
អំណះអំណាង ................................................................ vi
សេចក្តីសង្ខេបនៃការស្រាវជ្រាវ ................................................................ v
មាតិកា................................................................ vi

## ជំពូកទី១
## សេចក្តីផ្តើម

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ................................................................១
១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ................................................................១
១.៣ គោលបំណងនៃការស្រាវជ្រាវ................................................................២
១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ................................................................២
១.៤.១ ទំហំដែនកំណត់................................................................២
១.៤.២ វិសាលភាពនៃការស្រាវជ្រាវ................................................................២
១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ................................................................២
១.៦ សារៈសំខាន់នៃការស្រាវជ្រាវ................................................................២
១.៧ របនាសម្ព័ន្ធនៃការស្រាវជ្រាវ................................................................៣

## ជំពូកទី២
## ការរីកចម្រើននៃវិស័យហិរញ្ញវត្ថុ

២.១ លក្ខណៈទូទៅនៃការរីកច្រើនរីកនៃវិស័យហិរញ្ញវត្ថុ................................................................៤
២.១.១ និយមន័យហិរញ្ញវត្ថុ................................................................៤
២.១.២ ប្រវត្តិនៃហិរញ្ញវត្ថុ................................................................៤
២.១.៣ ទ្រឹស្តីនៃហិរញ្ញវត្ថុ................................................................៥
២.២ គោលការណ៍ក្នុងការជួយឱ្យវិស័យហិរញ្ញវត្ថុមានការរីកចម្រើន ................................................................៧
២.២.១ និយមន័យនៃគោលការណ៍ ................................................................៧
២.២.២ ប្រភេទនៃគោលការណ៍................................................................៧
២.២.៣ ទ្រឹស្តីនៃនៃគោលការណ៍ ................................................................៧
២.៣ ការរីកចម្រើននៃវិស័យហិរញ្ញវត្ថុនៅក្នុងសេដ្ឋកិច្ច................................................................៨

២.៣.១ និយមន័យសេដ្ឋកិច្ច ........ ៨
២.៣.២ ប្រវត្តិនៃសេដ្ឋកិច្ច ........ ៨
២.៣.៣ ទ្រឹស្តីនៃសេដ្ឋកិច្ច ........ ១០

## ជំពូកទី៣
## ការរីកចម្រើននៃវិស័យហិរញ្ញវត្ថុនៅកម្ពុជា

៣.១ ស្ថានភាពទូទៅនៃការរីកចម្រើននៃវិស័យហិរញ្ញវត្ថុនៅកម្ពុជា ........ ១៤
៣.១.១ ប្រវត្តិធនាគារជាតិនៃកម្ពុជា ........ ១៤
៣.១.២ ចក្ខុវិស័យ ឬបេសកកម្មរបស់វិស័យហិរញ្ញវត្ថុនៅកម្ពុជា ........ ១៦
៣.១.៣ ប្រភេទនៃវិស័យហិរញ្ញវត្ថុ ........ ១៦
៣.២ គោលការណ៍នៃការរីកចម្រើននៃវិស័យហិរញ្ញវត្ថុនៅកម្ពុជា ........ ២១
៣.២.១ ការធានាស្ថេរភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ........ ២១
៣.២.២ ការអភិវឌ្ឍវិស័យធនាគារនិងស្ថាប័នឥណទាន ........ ២២
៣.២.៣ ការលើកម្ពស់សេវាហិរញ្ញវត្ថុឌីជីថល ........ ២២
៣.២.៤ ការជម្រុញទីផ្សារហិរញ្ញវត្ថុក្នុងស្រុក និង Financial Inclusion ........ ២៣
៣.២.៥ ការចូលរួមអន្តរជាតិនិងជំរុញការវិនិយោគ ........ ២៤
៣.៣ ការរីកចម្រើននៃវិស័យហិរញ្ញវត្ថុចំពោះសេដ្ឋកិច្ចកម្ពុជា ........ ២៥

## ជំពូកទី៤
## ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

៤.១ ការវិភាគលើចំណុចខ្លាំង ........ ២៨
៤.២ ការវិភាគលើចំណុចខ្សោយ ........ ២៨

## ជំពូកទី៥
## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

៥.១ សេចក្តីសន្និដ្ឋាន ........ ៣០
៥.២ ការផ្តល់អនុសាសន៍ ........ ៣០
**ឯកសារយោង**
**ឧបសម្ព័ន**

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

បច្ចុប្បន្ននេះ ប្រទេសកម្ពុជាគឺជាប្រទេសមួយដែលត្រូវបានគេចាត់ទុកថា ជាប្រទេសដែលកំពុងមានការអភិវឌ្ឍន៍ នៅបណ្តាចំណោមប្រទេសផ្សេងៗក្នុងទ្វីបអាស៊ី នាពេលកន្លងទៅថ្មីៗនេះគេសង្កេតឃើញថា វិស័យហិរញ្ញវត្ថុ នៅក្នុងកម្ពុជាកំពុងតែមានការរីកលូតលាស់ជាបន្តបន្ទាប់គួរឱ្យកត់សម្គាល់ មិនតែប៉ុណ្ណោះ វិស័យហិរញ្ញវត្ថុ គឺជាកម្លាំងចលករដែលជួយជំរុញក្នុងការអភិវឌ្ឍន៍កំណើនសេដ្ឋកិច្ចជាតិ។ ជាក់ស្តែង នៅពេលដែលប្រទេសជាតិមួយមានកំណើនផ្នែកវិស័យហិរញ្ញវត្ថុ ប្រទេសជាតិនោះ ក៏មានកំណើនផ្នែកសេដ្ឋកិច្ចផងដែរនេះ សរបញ្ជាក់ឱ្យឃើញថា នៅពេលដែលប្រទេសមានការរីកចម្រើនផ្នែកវិស័យហិរញ្ញវត្ថុនោះ និងធ្វើឱ្យមានអ្នកវិនិយោគពីបណ្តាប្រទេសនានាមក ការបណ្តាក់ទុនកាន់តែច្រើនចូលមកក្នុងប្រទេស ដូចនេះវាជាកត្តាជួយឱ្យប្រជាជនមានការងារធ្វើព្រមទាំងជួយកាត់បន្ថយទៅលើបញ្ហាសេដ្ឋកិច្ច និងធ្វើឱ្យប្រទេសមានការរីកចម្រើនកាន់តែឆាប់រហ័ស។

មុននឹងវិស័យហិរញ្ញវត្ថុ មានការរីកលូតលាស់ដូចសព្វនេះ មានវិស័យជាច្រើនបានចូលរួមជាចំណែកធ្វើឱ្យមានការរីកដុះទៅមុខដូចជា វិស័យធនាគារ វិស័យមូលបត្រ និងវិស័យធានារ៉ាប់រងជាកត្តាសំខាន់ដែលបានជួយជំរុញឱ្យមានការរីកចម្រើនផងដែរ។ វិស័យធនាគារ (Bank Sector) នៅកម្ពុជាកំពុងវិវត្តន៍យ៉ាងឆាប់រហ័សដោយមានការចូលរួមសំខាន់ សម្រាប់ក្នុងការផ្តល់សេវាហិរញ្ញវត្ថុដល់ប្រជាជន និងជាចំណែកជួយដល់សេដ្ឋកិច្ចជាតិ រីឯវិស័យមូលបត្រ (Securities Sector) ជាផ្នែកសំខាន់នៃសេដ្ឋកិច្ចសារពើភ័ណ្ឌនៅកម្ពុជា ព្រោះវាជាទីផ្សារដែលផ្តល់ឱកាសក្នុងការវិនិយោគប្រមូលថវិកា ប្រកបដោយសុវត្ថិភាពសម្រាប់ក្រុមហ៊ុន និងអង្គភាពអាជីវកម្មមានការចម្រើនទៅលើទីផ្សារមូលបត្រ ចំណែកឯវិស័យធនារ៉ាប់រង (Insurance Sector) មានសារៈសំខាន់ក្នុងការជួយអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ដោយផ្តល់ឱ្យហិរញ្ញវត្ថុមានលំនឹង ឬស្ថេរភាព និងភាពរឹងមាំនៃស្ថាប័នឯកជនជាបន្ត។

ជាការពិតណាស់ដោយមើលឃើញថា នៅប្រទេសកម្ពុជាពិតជាមានការរីកចម្រើនផ្នែកវិស័យហិរញ្ញវត្ថុពិតមែន និងមានវិស័យជាច្រើនបានចូលរួមជាចំណែកយ៉ាងច្រើនសម្បូរបែបព្រមទាំងមានការវិនិយោគទុនពីគ្រប់បណ្តាប្រទេសនានាហេតុដូចនេះហើយ ទើបក្រុមយើងខ្ញុំធ្វើការជ្រើសរើសប្រធានបទស្តីពី"**ការរីកចម្រើននៃវិស័យហិរញ្ញវត្ថុនៅកម្ពុជា**" យកមកធ្វើការបកស្រាយនិងស្រាវជ្រាវសម្រាប់ចងក្រងទុកជាឯកសារផងដែរ។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

វិស័យហិរញ្ញវត្ថុ ជាផ្នែកមួយដ៏សំខាន់នៅក្នុងសេដ្ឋកិច្ចដែលពុំអាចខ្វះបាន និងមានតួនាទីយ៉ាងសកម្មក្នុងការជួយឱ្យសេដ្ឋកិច្ចជាតិមានលំនឹង ទោះបីជាវិស័យនេះជួយជាប្រយោជន៍ដល់ប្រទេសជាតិយ៉ាងណាក្តី ក៏វានៅតែមិនអាចជៀសផុតពីបញ្ហាដែរបង្ករឡើងតាមរយៈកត្តានានាបណ្តាលឱ្យមានការធ្លាក់ចុះ ដោយយល់ឃើញពីហានិភ័យ អាចកើតមានស្របពេលដែរវិស័យហិរញ្ញវត្ថុកំពុងមានការរីកចម្រើន។ ដើម្បីជាស្ពានឆ្លងដល់ការសិក្សាឱ្យកាន់តែស៊ីជម្រៅ អំពីការរីកចម្រើននៃវិស័យហិរញ្ញវត្ថុនៅកម្ពុជា ក្រុមយើងខ្ញុំធ្វើការរៀបចំនូវសំណួរចោទសួរចំនួន២ធំៗដូចខាងក្រោម៖

១. តើរាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលការណ៍យ៉ាងដូចម្ដេច ដើម្បីឱ្យវិស័យហិរញ្ញវត្ថុនៅកម្ពុជាមានការរីកចម្រើន?

២.តើវិស័យហិរញ្ញវត្ថុបានជួយធ្វើឱ្យសេដ្ឋកិច្ចមានការរីចម្រើនយ៉ាងដូចម្ដេច?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

- យល់ដឹងពីប្រភេទនៃវិស័យហិរញ្ញវត្ថុនីមួយៗ
- យល់ដឹងអំពីការរីកចម្រើនវិស័យហិរញ្ញវត្ថុនៅកម្ពុជា
- អាចស្វែងយល់ពីហានិភ័យដែរកើតឡើងចំពោះសេដ្ឋកិច្ច

## ១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៤.១ ទំហំ និងដែនកំណត់

ដោយសារពេលវេលាមានកំណត់ក្រុមយើងខ្ញុំ សូមលើកយកតែទិន្នន័យទាក់ទងដែលទៅនឹងការរីកចម្រើនវិស័យហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជាយកមកធ្វើការស្រាវជ្រាវ។

### ១.៤.២ វិសាលភាពនៃការស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវនេះក្រុមយើងខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវអំពីស្ថានភាពនៃការរីកចម្រើនរបស់វិស័យហិរញ្ញវត្ថុដោយយោងទិន្នន័យនៅក្នុងឆ្នាំ២០២៤។

## ១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះក្រុមយើងខ្ញុំបានធ្វើការជ្រើសរើសយកវិធីសាស្ត្រគុណវិស័យបែបពិពណ៌នាផ្ដោតទៅលើការវិភាគទិន្នន័យ និងឯកសារដែលពាក់ព័ន្ធប្រធានបទដើម្បីយកមកវិភាគនិងសិក្សាស្រាវជ្រាវក្នុងគោលបំណងបញ្ជាក់អំពីស្ថានភាពវិស័យហិរញ្ញវត្ថុនៅកម្ពុជា។

សម្រាប់សំណួរស្រាជ្រាវទី១ ៖ ការស្រាវជ្រាវនេះ ប្រើប្រាស់វិធីសាស្ត្រតាមបែបគុណវិស័យដូចជា ធ្វើការវិភាគលើរបាយការណ៍ កម្រងឯកសារនានា វិធីសាស្ត្រស្រាវជ្រាវតាមរយៈគេហទំព័រ បណ្ដាញសង្គមរបស់ធនាគារផ្ទាល់ការសិក្សាស្រាវជ្រាវព័ត៌មានខ្លះៗ បានមកពីបណ្ណាល័យរបស់សាកលវិទ្យាល័យវ៉ាន់ដា ការដកស្រង់នៅឯកសារនានា ទាក់ទងទៅមេរៀនទាំងឡាយណា ដែលពាក់ព័ន្ធនឹងប្រធានបទការអានកម្រងឯកសារផ្សេងៗរបាយការណ៍ចាស់ៗ ដែលសិស្សច្បងជំនាន់មុនបានធ្វើរួច និងធ្វើការសាកសួរទៅអ្នកគ្រូណែនាំ។

សម្រាប់សំណួរស្រាជ្រាវទី២ ៖ ការស្រាវជ្រាវនេះ ប្រើប្រាស់វិធីសាស្ត្រតាមបែបគុណវិស័យដូចជា ធ្វើការវិភាគលើរបាយការណ៍ កម្រងឯកសារនានា វិធីសាស្ត្រស្រាវជ្រាវតាមរយៈគេហទំព័រ បណ្ដាញសង្គមរបស់ធនាគារផ្ទាល់ការសិក្សាស្រាវជ្រាវព័ត៌មានខ្លះៗ បានមកពីបណ្ណាល័យរបស់សាកលវិទ្យាល័យវ៉ាន់ដា ការដកស្រង់នៅឯកសារនានា ទាក់ទងទៅមេរៀនទាំងឡាយណា ដែលពាក់ព័ន្ធនឹងប្រធានបទការអានកម្រងឯកសារផ្សេងៗ របាយការណ៍ចាស់ៗដែលសិស្សច្បងជំនាន់មុនបានធ្វើរួច និងធ្វើការសាកសួរទៅអ្នកគ្រូណែនាំ។

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

ក្នុងការស្រាវជ្រាវនីមួយៗ សុទ្ធសឹងតែទទួលបាននូវសារៈសំខាន់ ដោយឡែកពីគ្នាទៅតាមវិធីសាស្ត្រក៏ដូចជាលក្ខណៈខុសគ្នារបស់ប្រធានបទ។ ជាក់ស្ដែង ក្នុងការសិក្សាទៅលើប្រធានបទនេះ យើងទទួលបាននូវសារៈសំខាន់ដូចជា៖

**ក សម្រាប់អ្នកស្រាវជ្រាវ**

- ដើម្បីយល់ដឹងពីការវិវត្តន៍វិស័យហិរញ្ញវត្ថុនៅកម្ពុជា
- បង្កើនចំណេះដឹងផ្ទាល់ខ្លួនបូករួម និងទ្រឹស្តីពាក់ពន្ធ
- យល់ច្បាស់ពីផ្នែកសំខាន់ៗដែលមានក្នុងវិស័យហិរញ្ញវត្ថុ

**ខ សម្រាប់ស្ថាប័ន**

- ដឹងពីចំណុចខ្លាំងនិងចំណុចខ្សោយរបស់ខ្លួន
- បន្ថែមការកែលម្អទៅលើចំណុចខ្វះខាត
- ពង្រឹងគោលនយោបាយដើម្បីឱ្យការគ្រប់គ្រងហិរញ្ញវត្ថុកាន់តែមានប្រសិទ្ធភាព

**គ សម្រាប់សង្គមជាតិ**

- កត្តាដែលបណ្តាលឱ្យវិស័យហិរញ្ញវត្ថុមានការរីកចម្រើនយ៉ាងឆាប់រហ័ស
- បង្កើនចំណេះដឹងបន្ថែមទាក់ទៅនិងផ្នែកហិរញ្ញវត្ថុជាសាធារណៈ
- ជម្រុញឱ្យសារធារណជនស្គាល់កាន់តែច្បាស់ពីសារៈប្រយោជន៍នៃវិស័យហិរញ្ញវត្ថុចំពោះសេដ្ឋកិច្ចជាតិ

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងរចនាសម្ព័ន្ធ នៃការស្រាវជ្រាវរបស់ក្រុមយើងខ្ញុំបានកំណត់ និងបែងចែកជាសកម្មភាពទៅតាមជំណាក់កាលនីមួយៗដូចខាងក្រោមៈ

**ជំពូកទី១៖ សេចក្តីផ្តើម** បរិយាយសង្ខេបពីលំនាំបញ្ហា ចំណោទបញ្ហា គោលបំណងមូលហេតុនៃការស្រាវជ្រាវ ដែនកំណត់ និងវិសាលភាពហេតុផលមួយចំនួនដែលបង្កើតឱ្យមានការសិក្សាស្រាវជ្រាវ។

**ជំពូកទី២៖ រំលឹកទ្រឹស្តី** បង្ហាញពីនិយមន័យ ប្រវត្តិទូទៅដែលពាក់ព័ន្ធ និងទ្រឹស្តីរបស់អ្នកប្រាជ្ញដែលពាក់ព័ន្ធនឹងការសិក្សាស្រាវជ្រាវ។

**ជំពូកទី៣៖ លទ្ធផលនៃការស្រាវជ្រាវ** លើកឡើងពីស្ថានភាពទូទៅរបស់អង្គភាពរួមមានប្រវត្តិរបស់អង្គភាព បេសកកម្ម ទស្សនវិស័យ គោលនយោបាយរចនាសម្ព័ន្ធចាត់តាំង (ភារកិច្ច និងតួនាទី) និងបន្ទាប់មកត្រូវលើកឡើងឱ្យបានពីរឬបីចំណុចទៅលើការងារបច្ចេកទេសរបស់អង្គភាព។

**ជំពូកទី៤៖ ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ** វិភាគនឹងធ្វើការស្វែងយល់ពីចំណុចខ្លាំង និងចំណុចខ្វះខាតរបស់ប្រធានបទដែលពាក់ព័ន្ធ។

**ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍** សន្និដ្ឋានទៅលើចំណុចទាំងអស់ដែលមាននៅក្នុងអត្ថបទ និងផ្តល់អនុសាស៍ទៅលីចំណុចដែលខ្វះខាតដើម្បីធ្វើការកែលម្អិត។

# ជំពូកទី២
# ការរីកចម្រើននៃវិស័យហិរញ្ញវត្ថុ

## ២.១ លក្ខណៈទូទៅនៃការរីកចម្រើននៃវិស័យហិរញ្ញវត្ថុ

### ២.១.១ និយមន័យហិរញ្ញវត្ថុ

- ហិរញ្ញវត្ថុ គឺជាការពិពណ៌នាអំពីសកម្មភាពនានា ដែលទាក់ទងនឹងវិស័យធនាគារអានុភាព ឬបំណុលឥណទានទីផ្សារមូលធនប្រាក់រួម និងការវិនិយោគជាទូទៅហិរញ្ញវត្ថុតំណាងឱ្យការគ្រប់គ្រងប្រាក់ និងដំណើរការនៃការទទួលបានមូលនិធិដែលត្រូវការ។
- ហិរញ្ញវត្ថុត្រូវបានកំណត់ថាជាអំណោយនៃការគ្រប់គ្រងប្រាក់ហើយរួមមានសកម្មភាពដូចជា ការវិនិយោគ ការយកប្រាក់កម្ចី ការសងប្រាក់ ការរៀបចំថវិកា ការរក្សា និងការព្យាករណ៍[1]។
- ហិរញ្ញវត្ថុសំដៅដល់សកម្មភាពទាំងឡាយណា ដែលគ្រប់គ្រងថវិការហើយរួមបញ្ចូលទាំងសកម្មភាពដូចជា ការវិនិយោគ ការផ្តល់ប្រាក់កម្ចី ឥណទាន ការសន្សំ និងការព្យាករណ៍[2]។

### ២.១.២ ប្រវត្តិហិរញ្ញវត្ថុ

ប្រវត្តិហិរញ្ញវត្ថុ ជាប្រវត្តិសាស្ត្រដែលបង្ហាញពីរបៀប ដែលមនុស្សធ្វើការគ្រប់គ្រងធនធានក៏ដូចជាអនុវត្តន៍នូវការចំណាយ ប្រាក់ចំណេញ បំណុល និងវិនិយោគដែលមានដើមកំណើតមកពីការតម្រូវការធនធានក្នុងសង្គម បន្ទាប់មកបានអភិវឌ្ឍន៍ក្លាយទៅជាប្រព័ន្ធដ៏ស្មុគស្មាញ តាំងពីសម័យបុរាណរហូតមកដល់សម័យទំនើបដែលបែងចែកជាច្រើនសម័យកាលគិតចាប់ផ្តើមពីហិរញ្ញវត្ថុ(Ancient Period Finance)នាសម័យបុរាណមក។ នៅសម័យបុរាណប្រហែល៣០០០ឆ្នាំមុនគ.ស ដល់សតវត្សទី៥គឺជាកំណើតដំបូងនៃប្រព័ន្ធសេដ្ឋកិច្ចដែលមនុស្សបានបង្កើតដោយរកឃើញមាននៅក្នុងតំបន់អាគ្នេយ៍អាស៊ីរួមមាន អាណាចក្រ Mesopotamia អេហ្ស៊ីប ឥណ្ឌា ចិន បានប្រើប្រាស់ប្រព័ន្ធជួញដូរ (Barter System) កំណត់ត្រាឥណទានលើថាបអក្សរដី (clay tablets) និងច្បាប់ហិរញ្ញវត្ថុដូចជា Hammurabi (c. 1754 BCE) បន្តមកតំបន់លោកខាងលិចមានអាណាចក្រក្រិកនិងរ៉ូមបានអភិវឌ្ឍប្រព័ន្ធសេដ្ឋកិច្ចមានភាពប្រសើរឡើង និងការបង្កើតប្រាក់កាក់ជាផ្លូវការ (Coins) ធ្វើឡើងក្នុងទីក្រុង Lydia ។ហិរញ្ញវត្ថុមជ្ឈឹមសកល (Medieval Finance) ប្រហែលស្ថិតនៅក្នុងចន្លោះសតវត្សទី៥ដល់សតវត្សទី១៥សង្កេតឃើញមានការកើនឡើងនៃស្ថាប័នហិរញ្ញវត្ថុក្រុមហ៊ុនជួញដូររួមមាន Bance Monte dei Paschi (1472) សព្វថ្ងៃជាធនាគារដ៏ចំណាស់មានទីតាំងស្ថិតនៅក្នុងប្រទេស Italy ក្នុងសតវត្សទី១៣ដល់ទី១៥ ប្រទេសអ៊ីតាលីបានក្លាយជាមជ្ឈមណ្ឌលសំខាន់ សម្រាប់ពាណិជ្ជកម្មហិរញ្ញវត្ថុ ឧទាហរណ៍ The Medici Bank (បង្កើតឆ្នាំ១៣៩៧)នៅ Florence ជាធនាគារធំមួយដំបូងដែលអភិវឌ្ឍន៍បច្ចេកទេសហិរញ្ញវត្ថុស្មុគស្មាញដូចជាការគ្រប់គ្រងគណនី ផ្តល់ឥណទាន ផ្លាស់ប្តូររូបិយប័ណ្ណមិនតែប៉ុណ្ណោះ Medici Bank បានជួយលើកស្ទួយសេដ្ឋកិច្ចអឺរ៉ុបនិងមានឥទ្ធិពលទៅលើការអភិវឌ្ឍរបស់ធនាគារពិភពលោក សហគមន៍អាជីវកម្ម Hanseatic League ជាសមាគមអាជីវកម្មនិងជាក្រុងពាណិជ្ជកម្មក្នុងតំបន់សមុទ្រត្បូង Baltic Sea និងសមុទ្រត្បូង (North Sea) បង្កើតឡើងក្នុងសតវត្សទី១៣ដើម្បីការពារប្រយោជន៍ពាណិជ្ជកម្ម

[1] CFI. (2020, January 09).*"និយមន័យហិរញ្ញវត្ថុ"*. Retrieved from https://corporatefinanceinstitute.com/resources/wealth-management/what-i%20/ (Accessed February, 12 2025)

[2] Law and More. (2023, November 25). *"និយមន័យហិរញ្ញវត្ថុ"*. Retrieved from https://lawandmore.today (Accessed February, 12 2025)

របស់ក្រុងជាច្រើន ( ដូចជា Hamburg, Lübeck ) ការប្រើប្រាស់លិខិតឥណទាន ( Bills of Exchange )ក្នុងពាណិជ្ជកម្មអន្តរជាតិ អ៊ីស្លាមបានអភិវឌ្ឍន៍ហិរញ្ញវត្ថុអ៊ីស្លាម (Islamic Finance) នៅតំបន់ម៉ាស៊ីដូនបូតាអារ៉ាប៊ី និងអាហ្វ្រិកខាងជើងដោយគ្មានការប្រាក់(riba) ដោយផ្អែកលើច្បាប់ Shariah បង្កើតប្រព័ន្ធពាណិជ្ជកម្មលើការចែករំលែកហានិភ័យ (Mudarabah, Musharakah) គាំទ្រហិរញ្ញវត្ថុសុចរិតតាមច្បាប់សាសនា។ស្ថិតនៅក្នុងសម័យ Early Modern Finance សតវត្សទី១៥ដល់ទី១៨ដោយសារតែមានការចំណាយច្រើនចាំបាច់ត្រូវមានធនាគារដើម្បីគ្រប់គ្រងសាច់ប្រាក់រដ្ឋនិងសាច់ប្រាក់បម្រុង ហេតុនេះទើបមានការបង្កើតធនាគារជាតិនៃចក្រភពអង់គ្លេស (Bank of England 1694) បង្កើតឡើងសម្រាប់ផ្គត់ផ្គង់ប្រាក់កម្ចីហើយក៏ជាប្រភពសំខាន់នៃបរិក្ខារហិរញ្ញវត្ថុដូចជាការគ្រប់គ្រងអត្រាការប្រាក់ Riksbank (1668) ប្រទេសស៊ុយអែតត្រូវបានចាត់ទុកថាជាធនាគារជាតិមានប្រព័ន្ធបុរាណដំបូងជាងគេ ដែលនៅតែមានដំណើរការរហូតដល់សព្វថ្ងៃហើយគោលបំណងដើម គឺគ្រប់គ្រងបញ្ហាការផ្គត់ផ្គង់ប្រាក់និងឥណទានក្នុងសេដ្ឋកិច្ចជាតិ លើសពីនេះការរីកចម្រើននៃផ្សារហ៊ុន និងសារមូលបត្របូករួមទាំងការផ្លាស់ប្តូរហ៊ុន និងសារមូលបត្របានក្លាយជាផ្នែកសំខាន់នៃប្រព័ន្ធហិរញ្ញវត្ថុ។ប្រទេសបាជនល្លង់និងអង់គ្លេសបានបង្កើតទីផ្សារ stock exchange ដំបូងៗ (ឧ. Amsterdam Stock Exchange, London Stock Exchange[3] ។ នៅចន្លោះសតវត្សទី១៨-១៩ Rise of Modern Financial Markets កំណើតនៃទីផ្សារភាគហ៊ុនទំនើបបណ្តាញធនាគារ ការបោះប័ណ្ណបំណុលដោយរដ្ឋ ការប្រើប្រាក់ក្រដាសតំណាងឱ្យមាស (Gold Standard) និងការកកើតវិស័យធានារ៉ាប់រងដំបូង បន្តមកសតវត្សទី២០ ដំណើរការបង្កើតពិភពហិរញ្ញវត្ថុសកលមានកិច្ចព្រមព្រៀង (Bretton Woods, 1944) បង្កើតដោយ IMF និង World Bank ដើម្បីរួមគ្នាស្ថាបនាស្ថិរភាពអត្រាប្តូរប្រាក់បង្កើត Federal Reserve System (សហរដ្ឋអាមេរិក ១៩១៣) វិធានការត្រួតពិនិត្យប្រព័ន្ធប្រាក់ដុល្លារអាមេរិក[4]។ សតវត្សទី២១ ជាយុគសម័យនៃបច្ចេកវិទ្យាហិរញ្ញវត្ថុឌីជីថលផ្លាស់ប្តូរនៃប្រព័ន្ធសេដ្ឋកិច្ចជាសកល និងការចូលរួមរបស់បុគ្គលនិងគ្រឹះស្ថានបច្ចេកវិទ្យាក្នុងវិស័យហិរញ្ញវត្ថុមាន Internet Banking, Mobile Money, PayPal និងAlipay ជាសេវាកម្មផ្ទេរប្រាក់ឆាប់រហ័សនិងងាយស្រួល FinTech និង Blockchain ការប្រើប្រាស់បច្ចេកវិទ្យា Blockchain ដើម្បីបង្កើត Cryptocurrency ដូចជា Bitcoin ២០០៩ និង Ethereum ២០១៥ ផ្តល់ឱកាសឱ្យប្រព័ន្ធហិរញ្ញវត្ថុមានឯករាជ្យភាពពីធនាគារកណ្តាល DeFi និង Smart Contracts បច្ចេកវិទ្យាឱ្យសេវាកម្មហិរញ្ញវត្ថុធ្វើដោយស្វ័យប្រវត្តិដោយផ្អែកលើកិច្ចសន្យាឌីជីថលជាប្រភេទកិច្ចសន្យា(smart contracts)ហិរញ្ញវត្ថុបានវិវឌ្ឍទៅជា Digital Finance Blockchain និងរូបិយប័ណ្ណឌីជីថល (Cryptocurrency) លើសពីនេះការវិនិយោគ ESG បរិបទ COVID-19 និងការចូលរួមរបស់ AI, FinTech និង CBDC[5]។

### ២.១.៣ ទ្រឹស្តីរបស់ហិរញ្ញវត្ថុ

[3] Jessicapierce (2025-03-07). *"ប្រវត្តិហិរញ្ញវត្ថុ"*. Retrieved from https://en.m.wikipedia.org/wiki/Medici_Bank (Accessed February, 12 2025)

[4] CQF Blog. (2022-07-22). *"ប្រវត្តិហិរញ្ញវត្ថុ"*. Retrieved from https://www.cqf.com/blog/what-quantitative-finance-brief-history (Accessed February, 12 2025)

[5] Julia Kagan. (2024-03-25). *"ប្រវត្តិហិរញ្ញវត្ថុ"*. Retrieved from https://www.investopedia.com/terms/f/fintech.asp (Accessed February, 15 2025)

ទ្រឹស្តីរបស់ហិរញ្ញវត្ថុ ជាគំនិតផ្នែកវិទ្យាសាស្ត្រដែលបំភ្លឺអំពីរបៀបដែលមនុស្ស ឬស្ថាប័ន គ្រប់គ្រងប្រាក់ ការវិនិយោគ និងហានិភ័យ ទ្រឹស្តីទាំងនេះជាគន្លងគំនិតសម្រាប់ការសម្រេចចិត្តហិរញ្ញវត្ថុដូចជាការចំណាយ ការវិនិយោគ ការទទួលឥណទាន ការបង់បំណុល និងការគ្រប់គ្រងទុន ទ្រឹស្តីហិរញ្ញវត្ថុសំខាន់បំផុតដែលជាប្រភពនៃចំណេះដឹងក្នុងវិស័យហិរញ្ញវត្ថុមានចំនួន៧ទ្រឹស្តី។

ទ្រឹស្តី Modern Portfolio (Modern Portfolio Theory) ជាទ្រឹស្តីហិរញ្ញវត្ថុដែលបង្កើតឡើងដោយលោក Harry Markowitz នៅឆ្នាំ១៩៥២ បានពោលថា “Don’t put all your eggs in one basket” ទ្រឹស្តីនេះ ពន្យល់ពីរបៀបកែលម្អប្រាក់ចំណេញនៃការវិនិយោគដោយធ្វើការកាត់បន្ថយនូវហានិភ័យតាមរយៈការបែងចែកទុន(Diversification) ឬការបែងចែកការវិនិយោគទៅលើទ្រព្យសម្បត្តិច្រើនអាចជួយកាត់បន្ថយហានិភ័យ។ ការបែងចែកទុន ជាការវិនិយោគទៅលើទ្រព្យសម្បត្តិជាច្រើនប្រភេទ អាចបន្ថយហានិភ័យរួមទាំងករណីទ្រព្យទាំងនោះមាន (Low correlation) ចំពោះការបង្កើត (Portfolio Optimization) អ្នកវិនិយោគគួរបង្កើត “efficient portfolio” ដែលផ្តល់ប្រាក់ចំណេញខ្ពស់បំផុត សម្រាប់កម្រិតហានិភ័យណាមួយបន្ទាត់មក Efficient Frontier បង្ហាញទំនាក់ទំនងរវាងហានិភ័យ និងប្រាក់ចំណេញចំណុចលើនេះបង្ហាញថា ជាទុនដែល “ប្រសើរបំផុត” (best return for given risk)[6]។

ទ្រឹស្តី Capital Asset Pricing Model (CAPM) មានឥទ្ធិពលខ្លាំងមួយដែលបង្កើតដោយ លោក William Sharpe (1964), John Lintner និង Jan Mossin ដោយបានពោលថា “The greater the risk, the greater the expected return” មានន័យថាប្រាក់ចំណេញរំពឹងទុកនៃទ្រព្យសម្បត្តិ គឺអាស្រ័យលើទីផ្សារតែប៉ុណ្ណោះ Systematic Risk តាមរយៈតម្លៃ Beta (β) ហានិភ័យដែលមិនអាចបំបាត់បានហានិភ័យដែលទាក់ទងនឹងទិន្នន័យរបស់សេដ្ឋកិច្ច និងទីផ្សាររួមមិនអាចបំបាត់បាន ដោយការបែងចែកទុនប្រាក់ចំណេញ និងការរងចាំ Risk Premium វិនិយោគលើក្រុមហ៊ុនដែលមានហានិភ័យខ្ពស់ជំនួសមកវិញ ត្រូវបានគេទាមទារប្រាក់ចំណេញខ្ពស់។

ទ្រឹស្តី Efficient Market Hypothesis (EMH) គឺជាទ្រឹស្តីហិរញ្ញវត្ថុ ដ៏មានឥទ្ធិពលខ្លាំងដែលបង្កើតដោយលោក Eugene Fama នៅឆ្នាំ១៩៧០ ពោលថា “You can’t beat the market-because all information is already priced in” សំដៅលើតម្លៃទ្រព្យសម្បត្តិជានិច្ចបានសម្រួលព័ត៌មានទាំងអស់រួចហើយ Transparency Access, Market, Reaction ទីផ្សារប្រសិទ្ធនឹងប្រតិកម្មយ៉ាងទាន់ពេលដល់ព័ត៌មានថ្មីៗគ្មាន “undervalued” ឬ “overvalued” យូរឡើយមិនអាច Beat the Market ដោយការវិភាគជាផ្ទាល់ Analysis techniques (fundamental or technical)[7]។

ទ្រឹស្តី Arbitrage Pricing Theory (APT) គឺជាទ្រឹស្តីហិរញ្ញវត្ថុដ៏សំខាន់ដែលបង្កើតឡើងដោយ Stephen Ross បានពោលថា “Asset returns are driven by multiple macroeconomic factors, not just market beta” អះអាងថាតម្លៃនៃទ្រព្យសម្បត្តិអាចប៉ាន់ប្រមាណតាមរយៈកត្តាជាច្រើនដែលមានឥទ្ធិពលលើប្រាក់ចំណេញ។

[6] Harry Markowitz. (2022-03-01) *ទ្រឹស្តីហិរញ្ញវត្ថុ*. Retrieved from https://www.jstor.org/stable/2975974 (Accessed February, 15 2025)

[7] Ann C. Logue. (2025-04-08). *ទ្រឹស្តីហិរញ្ញវត្ថុ*. Retrieved from https://www.britannica.com/money/what-is-the-efficient-market-hypothesis (Accessed February, 15 2025)

ទ្រឹស្តី Behavioral Finance គឺជាទ្រឹស្តីដែលហិរញ្ញវត្ថុដ៏សំខាន់ដែលបង្កើតឡើងដោយលោក Daniel Kahneman, Amos Tversky និង Richard Thaler និយាយអំពីវិស័យមួយនៃហិរញ្ញវត្ថុដែលសិក្សាពីរបៀបដែលអារម្មណ៍បុគ្គលិកលក្ខណៈ និងលក្ខណៈចិត្តវិជ្ជាឥទ្ធិពលដល់ការទិញលក់និងសេចក្តីសម្រេចផ្នែកហិរញ្ញវត្ថុ។

ទ្រឹស្តី Agency Theor គឺជាទ្រឹស្តីដែលហិរញ្ញវត្ថុដ៏សំខាន់ដែលបង្កើតឡើងដោយ Jensen and Meckling សិក្សាអំពីទំនាក់ទំនងរវាង "Principal" (ម្ចាស់) និង "Agent" (អ្នកគ្រប់គ្រង) បញ្ហាដែលកើតឡើងពេលឯកសារអាជីវកម្មមិនស្របគ្នា ឬគ្មានការត្រួតពិនិត្យសមរម្យជាឧទាហរណ៍ shareholder គឺជា principal និង CEO ឬអ្នកគ្រប់គ្រងគឺជា agent។

ទ្រឹស្តី Modigliani–Miller Theorem (M&M) គឺជាទ្រឹស្តីហិរញ្ញវត្ថុដ៏សំខាន់ដែលបង្កើតឡើងដោយលោក Franco Modigliani និង Merton Miller នៅឆ្នាំ១៩៥៨បានពោលថា "Under certain assumptions capital structure does not affect firm value" មានន័យថាតម្លៃក្រុមហ៊ុនមិនពឹងផ្អែកលើរចនាសម្ព័ន្ធឥណទាននិងឈ្មួញ (capital structure) តែពឹងផ្អែកលើសមត្ថភាពកនុងការបង្កើតប្រាក់ចំណេញ[8]។

## ២.២ គោលការណ៍ក្នុងការជួយឱ្យវិស័យហិរញ្ញវត្ថុមានការរីកចម្រើន

### ២.២.១ និយមន័យគោលការណ៍

- គោលការណ៍ជាវិធានទូទៅដែលផ្តល់នូវមូលដ្ឋានឬប្រភពដើមនៃបទដ្ឋានគតិយុត្ត។
- គោលការណ៍ជាវិធានទូទៅ ឬទ្រឹស្តីមួយដែលផ្តល់នូវមូលដ្ឋាន ឬប្រភពដើមនៃបទដ្ឋានគតិយុត្ត។គោលការណ៍ជាច្បាប់ ឬទស្សនវិជ្ជា ឬគំនិតដើមសម្រាប់អនុវត្ត ឬដឹកនាំសកម្មភាពណាមួយឱ្យមានទិសដៅត្រឹមត្រូវ និងមានប្រសិទ្ធភាព។
- គោលការណ៍ ជាវិធានគតិយុត្តដែលបង្កើតដោយអត្ថបទច្បាប់ដែលមានលក្ខណៈទូទៅក្នុងគោលបំណងជានាការអនុវត្តផ្សេងៗ ហើយមានតម្លៃគតិយុត្តខ្ពស់[9]។

### ២.២.២ ប្រវត្តិនៃពាក្យគោលការណ៍

លោកម៉ង់តេរីយើជាទស្សនវិទូនយោបាយ និងជាអ្នកប្រវត្តិរបស់បារាំងដែលត្រូវបានគេស្គាល់ថាជាស្ថាបនិកសង្គមវិទ្យា និងជាបិតានៃវិទ្យាសាស្រ្តនយោបាយគាត់បានលះបង់ការងាររបស់គាត់ទាំងអស់ក្នុងឆ្នាំ១៧២៦ ហើយការសញ្ជឹងគិត និងធ្វើការទៅក្រៅប្រទេសមាន អ៊ីតាលី ហុងគ្រី ហូឡង់ និងប្រទេសអង់គ្លេសជាដើម។គោលការណ៍(ស្នាដៃ)សំខាន់របស់គាត់គឺការផ្តត់ផ្គង់ច្បាប់ និងការបែងចែកអំណាចក្នុងរដ្ឋលោកបានកំណត់គោលការណ៍មួយចំនួននៅក្នុងស្នាដៃដ៏ល្បីរបស់គាត់ឈ្មោះ The Spirit of Low (1728-1748) ស្នាដៃនេះបានបោះពុម្ពលើកទីមួយក្នុងឆ្នាំ១៧៤៨។ លោកម៉ង់តេរីយើបានធ្វើការកត់សម្គាល់ថាមានមនុស្សជាច្រើនដែលដឹកនាំមនុស្សរួមមាន អាកាសធាតុ សាសនា ច្បាប់ និងគោលការណ៍ក្នុងអតីតកាលដូចជាសីលធម៌ទម្លាប់ប្រពៃណី លទ្ធផលទាំងនេះបង្កើតបានជាប្រលឹងទូទៅរបស់ប្រជាជន។ គោលការណ៍គឺជាសំណើឬគុណតម្លៃដែលជាមគ្គុទ្ទេសក៍សម្រាប់វាយតម្លៃនៅក្នុងច្បាប់ ហើយវាគឺជាច្បាប់មួយដែលត្រូវមានឬ

[8] James Chen (2024-09-25).*"ទ្រឹស្តីហិរញ្ញវត្ថុ"*. Retrieved from https://www.investopedia.com/terms/m/modigliani-millertheorem.asp (Accessed February, 15 2025)

[9] Lawkh (2022-08-12).*"និយមន័យគោលការណ៍"*. Retrieved from https://law2021.wordpress.com-principle/ (Accessed February, 15 2025)

ជាធម្មតាត្រូវធ្វើតាមវាអាចត្រូវបានអនុវត្តតាមបំណងប្រាថ្នា ឬវាអាចជាផលវិបាកដែលជៀសមិនរួចនៃអ្វីមួយ ដូចជាច្បាប់ដែលសង្កេតឃើញនៅក្នុងធម្មជាតិ ឬរបៀបដែលប្រព័ន្ធមួយត្រូវបានសាងសង់។

**២.២.៣ ទ្រឹស្តីគោលការណ៍**

ទ្រឹស្តីគោលការណ៍ គឺជាទ្រឹស្តីដែលចេញប្រើជាគោលសម្រាប់អនុវត្តកិច្ចការឱ្យត្រូវតាមបែបផែនឬជាតម្លៃដែលជាការណែនាំឬការវាយតម្លៃ នៅក្នុងច្បាប់វាជាច្បាប់មួយដែលត្រូវអនុវត្តតាមធម្មតាត្រូវតែអនុវត្តតាមជានដោយខានពុំបានម៉្យាងទៀតគោលការណ៍មានមុខងារពាក់ព័ន្ធពីរនៅក្នុងប្រព័ន្ធច្បាប់។ លើសពីនេះទៅទៀតគោលការណ៍មានសារៈសំខាន់ណាស់ក្នុងដំណើរការនៃការគ្រប់គ្រងអង្គភាព ក្រុមហ៊ុន ឬរោងចក្រផងដែរ នៅក្នុងចំណុចការគ្រប់គ្រចំណាយអាចត្រូវបានគេកំណត់ថាជាការធ្វើផែនការ ការរកប្រភព ការបែងចែក ការត្រួតពិនិត្យ និងការវាយការណ៍នូវរាល់ប្រតិបត្តិការដែលកើតមាននៅក្នុងអង្គភាពទាំងអស់ដើម្បីងាយស្រួលក្នុងការតាមដានចំណាយរាល់ការិយបរិច្ឆេទរបស់ក្រុមហ៊ុន ការចេះគ្រប់គ្រងចំណាយគឺមានសារៈសំខាន់នៅក្នុងអង្គភាពនីមួយៗ ព្រោះថាបើក្រុមហ៊ុនខ្វះនូវបច្ចេកទេសក្នុងការគ្រប់គ្រងចំណាយងាយនឹងធ្វើឱ្យអង្គភាពឆាប់ទទួលរងនូវហានិភ័យដែលកើតមានឡើងនៅក្នុងអង្គភាព។ ដូច្នេះហើយបានជាគ្រប់អង្គភាពទាំងអស់តែងតែទាមទារឱ្យមានគោលការណ៍ច្បាស់លាស់ក្នុងការគ្រប់គ្រងចំណាយ ដើម្បីឱ្យក្រុមហ៊ុនមានដំណើរការល្អទទួលបានផលចំណេញច្រើន ជាពិសេសអាចជៀសវាងនូវរាល់ហានិភ័យផ្សេងៗដែលអាចកើតមាននៅក្នុងក្រុមហ៊ុនដោយសារតែការចេះគ្រប់គ្រងនិងការបែងចែកការប្រើប្រាស់ចំណាយនៅក្នុងអង្គភា[10]។

## ២.៣ ការរីកចម្រើននៃវិស័យហិរញ្ញវត្ថុនៅក្នុងសេដ្ឋកិច្ច

### ២.៣.១ និយមន័យសេដ្ឋកិច្ច

- សេដ្ឋកិច្ចជាការសិក្សាអំពីយុទ្ធសាស្ត្ររបៀបប្រើប្រាស់ធនធាន ដើម្បីបំពេញបំណងដែលគ្មានព្រំដែនរបស់មនុស្សដែលមានប្រព័ន្ធទាក់ទិននឹងប្រព័ន្ធផលិតកម្មផ្នែកសេដ្ឋកិច្ចលនិងឧស្សាហកម្មប្រព័ន្ធបែងចែក (ផ្នែកពាណិជ្ជកម្ម) និងប្រព័ន្ធប្រើប្រាស់ទំនិញសេដ្ឋកិច្ច (ផ្នែកអតិថិជនផ្នែកគមនាគមន៍ និងដឹកជញ្ជូន)។
- សេដ្ឋកិច្ចគឺជាសំណុំនៃទំនាក់ទំនងផលិតកម្មការប្រើប្រាស់ ការទិញដូរ ការបែងចែងធនធានកម្រទាំងឡាយនៅក្នុងសង្គមឬក៏ទាក់ទងទៅនឹង[11]។
- សេដ្ឋកិច្ច គឺជាការសិក្សាស្រាវជ្រាវអំពីរបៀបដែលបុគ្គលក្រុមគ្រួសារចេះលៃលកប្រើប្រាស់នូវធនធានដែលមាននៅក្នុងការផលិតចេញជាផលិតផល និងបង្កើតសេវាកម្មផ្សេងៗដើម្បីបម្រើសេចក្តីត្រូវការឥតព្រំដែនរបស់មនុស្ស[12] ។
- សេដ្ឋកិច្ចគឺជាការសិស្សាអំពីការប្រើប្រាស់ធនធានកម្រឱ្យមានប្រសិទ្ធភាព ដើម្បីបំពេញតម្រូវការរបស់មនុស្សដែលគ្មានដែនកំណត់[13]។

[10] ដកស្រង់ចេញពីសារណាជំនាន់ទី១៩ឆ្នាំ២០២២ ប្រវត្តិនិងទ្រឹស្តីគោលការណ៍

[11] Chanheng Meng (2021-05-04). *"និយមន័យសេដ្ឋកិច្ច"* Retrieved from https://www.khsearch.com/qna/13654 (Accessed February, 17 2025)

[12] ចំណេះដឹងទូទៅ (2019-04-29). *"និយមន័យសេដ្ឋកិច្ច"*. Retrieved from https://www.khsearch.com/qna/19300 (Accessed February, 17 2025)

[13] Ishare(2017-06-08). *"និយមន័យសេដ្ឋកិច្ច"*. Retrieved from https://ishare77.blogspot.com/2017/06/what-is-economics.html (Accessed February, 17 2025)

**២.៣.២ ប្រវត្តិនៃសេដ្ឋកិច្ច**

ប្រវត្តិសេដ្ឋកិច្ច(Economic History) គឺជាការសិក្សាពីវិធីដែលសេដ្ឋកិច្ចបានអភិវឌ្ឍន៍ឡើង នៅក្នុងអំឡុងពេលប្រវត្តិសាស្ត្រវាអនុវត្តន៍ការវិភាគសេដ្ឋកិច្ច ដើម្បីយល់អំពីស្ថានភាពសេដ្ឋកិច្ចតែម្តងនឹងស្ថានភាសង្គម និងនយោបាយនៅក្នុងយុគ្គនីមួយៗ។

សេដ្ឋកិច្ចបុរាណ(Ancient Economy) សំដៅទៅលើប្រព័ន្ធសេដ្ឋកិច្ចដែលមាននៅក្នុងសម័យបុរាណមុនសម័យទំនើបដែលត្រូវបានគេវាយតម្លៃថាជា សេដ្ឋកិច្ចមានលក្ខណៈសង្គមវិបីគ្មានទីផ្សារដែលដំណើរការផ្អែកលើការប្រកួតប្រជែងដូចសេដ្ឋកិច្ចសម័យថ្មីទេ វាស្ថិតនៅក្នុងចំណុចប្រសព្វរវាងកសិកម្មសាសនា អំណាចនយោបាយ។ លក្ខណៈសំខាន់ៗ នៃសេដ្ឋកិច្ចបុរាណសេដ្ឋកិច្ចផ្អែកលើកសិកម្មនិងចិញ្ចឹមសត្វ ប្រជាជនបម្រើសេដ្ឋកិច្ចតាមរយៈការផលិតអាហារដោយដៃ សេដ្ឋកិច្ចផ្អែកលើជីវភាពនិងសហគមន៍គ្រួសារ និងភូមិជាអង្គភាពផលិត និងប្រើប្រាស់ដោយខ្លួនឯងមិនមានទីផ្សារដែលមានរចនាសម្ព័ន្ធច្បាស់លាស់ ជួញដូរតិចតួច និងផ្អែកលើការប្តូរផលិតផល (barter economy)។ ការគ្រប់គ្រងអំណាចដោយសាសនា ឬស្តេចវត្ថុជាតុដើមសំខាន់ៗ និងការចែកចាយធនធាន គឺអនុវត្តន៍តាមបញ្ញាច្បាប់សង្គមនិងសាសនា ការវិវត្តន៍ពីសេដ្ឋកិច្ចបុរាណទៅសេដ្ឋកិច្ចសម័យថ្មីពីប្រព័ន្ធផ្អែកលើជីវភាពនិងអំណាចសាសនាទៅទីផ្សារសេរី និងកំណត់តម្លៃតាមតម្រូវការផ្គត់ផ្គង់ពីអភិបាលកណ្តាលសម្បទានទៅកាន់ទ្រព្យសម្បត្តិឯកជននិងជួញដូរអន្តរជាតិ។

សេដ្ឋកិច្ចកាលបុរាណ (Classical Economy) គឺជាសម្ព័ន្ធគំនិតសេដ្ឋកិច្ចដែលកើតឡើងនៅក្នុងសតវត្សទី១៨និងទី១៩នៅអឺរ៉ុប(ជាពិសេសនៅអង់គ្លេស)ឆ្លើយតបនឹងការផ្លាស់ប្តូរសេដ្ឋកិច្ចក្នុងសម័យបដិវត្តឧស្សាហកម្មវាប្រកាសថាទីផ្សារដើរដោយខ្លួនឯងតាមរយៈ "ដៃអរូបី" (invisible hand) ហើយសេដ្ឋកិច្ចត្រូវឱ្យមានសេរីភាពខ្ពស់ពុំមានការតខ្ទាប់ដោយរដ្ឋជាចម្បងនោះទេ។ លក្ខណៈសំខាន់ៗនៃClassical Economics ទីផ្សារសេរីប្រព័ន្ធទីផ្សារដើរតាមតម្រូវការ និងផ្គត់ផ្គង់ដោយគ្មានការជ្រៀតចូលពីរដ្ឋ។ ការផលិតជាគន្លងសំខាន់សេដ្ឋកិច្ចផ្អែកលើការពង្រឹងផលិតកម្ម ជាពិសេសផលិតកម្មឧស្សាហកម្មច្បាស់លាស់ក្នុងសំណុំច្បាប់ធម្មជាតិទស្សនៈថាមាន "ច្បាប់ធម្មជាតិ" (natural laws) គ្រប់គ្រងសេដ្ឋកិច្ចដូចជាច្បាប់ផ្គត់ផ្គង់តម្រូវការនិងការបែងចែកទ្រព្យសម្បត្តិជំរុញការវិភាគពីតម្លៃឬប្រាក់ចំណេញរបស់ដីកម្មករ និងទ្រព្យធន។

សេដ្ឋកិច្ចមជ្ឈមសម័យ (Medieval Economy) ឆ្នាំ៥០០-១៥០០ គ.សគឺជាសេដ្ឋកិច្ចដែលមានរចនាសម្ព័ន្ធផ្អែកលើប្រព័ន្ធសេរីនយោបាយ និងសាសនាដោយមានការតម្រង់អំណាចសេដ្ឋកិច្ចក្នុងដៃអ្នកដឹកនាំសាសនា និងភូមិមន្ត្រីអភិបាលក្នុងប្រព័ន្ធសេរីនិយម (Feudalism) វាកើតឡើងបន្ទាប់ពីការដួលរលំរបស់អាណាចក្ររ៉ូម និងបន្តរហូតដល់សម័យ Renaissance លក្ខណៈសំខាន់ៗនៃសេដ្ឋកិច្ចមជ្ឈមសម័យប្រព័ន្ធសេរីនិយម (Feudal Economy) ដីជាធនធានសំខាន់បំផុតគេបែងចែកដីឱ្យអ្នកមាននិងជ្រើសយកការងារពីប្រជាជន serfs សេដ្ឋកិច្ចជីវភាព (Subsistence Economy) ប្រជាជនផលិតសម្រាប់ប្រើប្រាស់ក្នុងគ្រួសារជាងជួញដូរការគ្រប់គ្រងដោយសាសនាសាសនាចក្រកាតូលិច (Catholic Church) មានឥទ្ធិពលខ្លាំងលើការបែងចែកសម្បទានការផលិតទីផ្សារមិនទាន់អភិវឌ្ឍន៍ការជួញដូរទំនិញមានកំណត់តាមទីផ្សារភូមិ (local market) និងប្រើប្រាស់រូបិយប័ណ្ណតិច។

សេដ្ឋកិច្ចសម័យឧស្សាហកម្ម (Industrial Economy) ប្រមាណឆ្នាំ១៧៥០ ដល់ឆ្នាំ១៩០០ ឡើងជាការផ្លាស់ប្តូរ ដ៏សំខាន់បំផុតក្នុងប្រវត្តិសាស្ត្រសេដ្ឋកិច្ច មនុស្សបានចាប់ផ្តើមនៅចក្រភពអង់គ្លេសស្ទើតែចុង

សតវត្សទី១៨ ហើយបានបន្តទៅសហរដ្ឋអាមេរិកអឺរ៉ុប និងប្រទេសផ្សេងៗ ប្រើបច្ចេកវិទ្យាម៉ាស៊ីនរោងចក្រ ដើម្បីបំលែងពីសេដ្ឋកិច្ចកសិកម្មទៅសេដ្ឋកិច្ចផលិតកម្មធុនធ្ងន់។ លក្ខណៈសំខាន់ៗនៃសេដ្ឋកិច្ចឧស្សាហកម្ម ប្រព័ន្ធរោងចក្រ គឺការផលិតត្រូវបានមើលឃើញថាជា ចំណុចកណ្តាលចម្ងាយពីការផលិតផ្ទះឯកជនទៅការ ផលិតក្នុងរោងចក្រ ការប្រើម៉ាស៊ីនបច្ចេកវិទ្យាថ្មីៗ (steam engine, power loom, spinning jenny) ជំនួសការ ធ្វើដៃសាមញ្ញ ការធ្វើឱ្យទីក្រុងមានរីកចម្រើនប្រជាជនផ្លាស់ទីចេញពីភូមិទៅទីក្រុង ដើម្បីធ្វើការផលិត urbanization ការអភិវឌ្ឍផ្លូវ និងធនាគារទីផ្សារចម្រុះអន្តរជាតិកើនឡើងនៃវិស័យហិរញ្ញវត្ថុ និងការកើត ឡើងនៃ "stock markets" ការកើនឡើងនៃជីវកម្មពលកម្មក្លាយជាធនធានគោល ហើយជនជាតិមួយចំនួន ក្លាយជាសេដ្ឋីបង្កើតអំណាចថ្មី (bourgeoisie)។

សេដ្ឋកិច្ចសម័យទំនើប (Modern Economy) ឆ្នាំ១៩០០-បច្ចុប្បន្នគឺជាវឌ្ឍនភាពបន្ទាប់ពីសម័យ ឧស្សាហកម្មដែលមានបច្ចេកវិទ្យាថ្មីៗចំណេះដឹងវែងឆ្ងាយ និងប្រព័ន្ធសេដ្ឋកិច្ចស្មុគស្មាញជាងមុនកើតឡើង ក្នុងបរិបទដែលប្រទេសចំណាស់ៗ បានបញ្ចប់ការផលិតលើគ្រឿងបន្លាស់ និងការជ្រៀតចូលទៅក្នុងសេដ្ឋកិច្ច សេវាកម្មព័ត៌មាន និងឌីជីថល។ លក្ខណៈសំខាន់ៗនៃសេដ្ឋកិច្ចទំនើប ដោយផ្អែកទៅលើចំណេះដឹងការ ស្រាវជ្រាវ និងបច្ចេកវិទ្យាជាមូលដ្ឋានក្នុងការផលិតក៏ដូចជាការរីកចម្រើនសេដ្ឋកិច្ច។ វិស័យសេវាកម្មគ្រប់គ្រង សេដ្ឋកិច្ចផលិតកម្មកាត់បន្ថយខណៈវិស័យសេវាកម្មដូចជា សណ្ឋាគារ ធនាគារ បច្ចេកវិទ្យា កើនឡើងយ៉ាង លឿនបរទេសនិយម និងសេដ្ឋកិច្ចពិភពលោកមានប្រទេសជាច្រើនចូលរួម ក្នុងទីផ្សារពិភពលោក និងមាន សេដ្ឋកិច្ចខាងក្រៅមានឥទ្ធិពលយ៉ាងខ្លាំងលើសេដ្ឋកិច្ចក្នុងស្រុកបច្ចេកវិទ្យាឌីជីថលដូចជា blockchain, cloud computing, AI, IoT ប្រែប្រួលរបៀបផលិតប្រើប្រាស់ធនធានសេដ្ឋកិច្ចរដ្ឋជានាជីវភាព និងបញ្ហាសង្គមការ ពង្រឹងបណ្តាញសុវត្ថិភាពសង្គមពិភពលោកកំពុងដោះស្រាយបញ្ហាប្រឈមដូចជាភាពក្រីក្រ[14]។

**២.៣.៣ ទ្រឹស្តីរបស់សេដ្ឋកិច្ច**

ទ្រឹស្តីសេដ្ឋកិច្ច (Economic Theories) ជាទ្រឹស្តីឬសំនុំគោលការណ៍ដែលបង្កើតឡើង ដើម្បីពិភាក្សា និងពន្យល់ពីរបៀបដំណើរការនៃប្រព័ន្ធសេដ្ឋកិច្ចទ្រឹស្តីទាំងនេះ អាចត្រូវបានប្រើដើម្បីធ្វើការព្យាករណ៍សិក្សា អំពីឥទ្ធិពលនៃគោលនយោបាយសេដ្ឋកិច្ច និងដោះស្រាយបញ្ហាសេដ្ឋកិច្ច ខាងក្រោមជាការពិពណ៌នាអំពី ទ្រឹស្តីសេដ្ឋកិច្ចសំខាន់ៗជាចម្បង។

ទ្រឹស្តីសេដ្ឋកិច្ចបុរាណ (Classical Economics Theory) គឺជាទ្រឹស្តីសេដ្ឋកិច្ចមួយដែលបានកើតឡើង នៅសតវត្សទី១៨ដល់ទី១៩ ជាបដិសន្ធិការធំមួយក្នុងប្រវត្តិសាស្ត្រសេដ្ឋកិច្ចដែលបានបង្កើតឡើងដោយសេដ្ឋ កិសាស្ត្រដូចជា Adam Smith, David Ricardo និង John Stuart Mill ចំណុចពិសេសនៃទ្រឹស្តីសេដ្ឋកិច្ច បុរាណមានការគាំទ្រទីផ្សារសេរីប្រឆាំង និងការជ្រៀតជ្រែករបស់រដ្ឋហើយជឿលើសមត្ថភាពសម្របសម្រួល ដោយខ្លួនឯង។ គោលការណ៍សំខាន់ៗនៃទ្រឹស្តីសេដ្ឋកិច្ចបុរាណមាន៤ចំណុចធំៗ គឺទីមួយច្បាប់ទីផ្សារសេរី (Free Market/Invisible Hand) របស់លោក Adam Smith បានជឿថាប្រសិនបើសេដ្ឋកិច្ចត្រូវបានទុកឱ្យ ដំណើរការជាសេរីដោយគ្មានការជ្រៀតជ្រែកពីរដ្ឋ (laisser-faire) អាចសម្របសម្រួលខ្លួនឯងតាមរយៈ "Invisible Hand" ដើម្បីធានាសមាមាត្រនៃបរិមាណផ្គត់ផ្គង់និងបរិមាណតម្រូវការ ការកំណត់តម្លៃតាម

[14] PURDUEGLOBAl. Tilahun Ayanou. (2015-01-23). *"ទ្រឹស្តីសេដ្ឋកិច្ច"* Retrieved from https://www.purdueglobal.edu/blog/business/us-economic-timeline-history (Accessed February, 17 2025)

លក្ខខណ្ឌផ្សារ (Price Determination) តម្លៃនៃទំនិញត្រូវបានកំណត់ការផ្គត់ផ្គង់ និងតម្រូវការការប្រែប្រួលតម្លៃនឹងជួយធ្វើឱ្យទីផ្សារសម្របសម្រួលវិញទៅមក។ ទីពីរច្បាប់នៃប្រយោជន៍តិចតួច(Diminishing Returns) ការបន្ថែមធនធានទៅផលិតកម្មមួយចំនួននឹងផ្តល់ផលចំណេញកាន់តែតិចតួចបន្តិចៗ។ ទីបីការធ្វើជំនួញជាសាច់ញាតិនៃកំណើនសេដ្ឋកិច្ច (Trade and Specialization) David Ricardo បានបង្ហាញពីគោលការណ៍ Comparative Advantage ដែលនិយាយថាប្រទេសមួយគួរតែជំនាញលើផលិតផលដែលខ្លួនមានប្រសិទ្ធភាពខ្ពស់ជាងនិងធ្វើជំនួញជាមួយអ្នកដទៃ។ ទីបួនការចាប់ផ្តើមពីផលិតកម្ម (Production-Oriented Focus) Classical Economics ផ្តោតលើផលិតកម្មជាចម្បងដោយជឿថាផលិតផលជាច្រើននឹងបង្កើតតម្រូវការរបស់ខ្លួន (Say's Law: "Supply creates its own demand") អ្នកបង្កើតនិងអភិវឌ្ឍន៍ទ្រឹស្តីនេះមាន Adam Smith ស្នាដៃ The Wealth of Nations (1776) បង្ហាញពីរបៀបដែលទីផ្សារសេរីអាចបង្កើតសេដ្ឋកិច្ចរីកចម្រើន លោក David Ricardo បង្កើតទ្រឹស្តី Comparative Advantage និងច្បាប់ Diminishing Returns។Thomas Malthus ធ្វើការវិភាគលើប្រជាជននិងជំរុញគំនិតអំពីកំណត់ធនធានធម្មជាតិJohn Stuart Mill បន្ថែមចំណេះដឹងអំពីសិទ្ធិសង្គម និងការកែប្រែច្បាប់ទីផ្សារដោយសេរីនិងស្មើភាព។

ទ្រឹស្តីសេដ្ឋកិច្ចនិយមថ្មី (Neoclassical Economics) គឺជាទ្រឹស្តីសេដ្ឋកិច្ចដែលកើតឡើងក្រោយទ្រឹស្តីសេដ្ឋកិច្ចបុរាណ (Classical Economics) ចាប់ពីសតវត្សទី១៩-២០ បាននាំមកនូវការផ្លាស់ប្តូរធំៗដោយផ្តោតលើជម្រើសសេដ្ឋកិច្ចផ្ទាល់ខ្លួន (individual decision-making) និងវិភាគតម្លៃតាម (marginal analysis) បន្ថែមពីនេះ Neoclassical Economics ជាទ្រឹស្តីមានឥទ្ធិពលខ្លាំងនៅសតវត្សទី២០ហើយវាមានសារៈសំខាន់ណាស់ចំពោះសេដ្ឋកិច្ចទីផ្សារសេរី ទោះជាយ៉ាងណាក្តី វាក៏ត្រូវបានបន្តអភិវឌ្ឍន៍និងចម្រុះឡើងដោយទ្រឹស្តីសេដ្ឋកិច្ចទំនើបជាច្រើនដូចជា Keynesian, Behavioral economics, Institutional economicsគោលការណ៍សំខាន់ៗនៃ Neoclassical Economics មានជម្រើសសេដ្ឋកិច្ចផ្ទាល់ខ្លួន (Rational Choice Theory) ជឿថាបុគ្គលទាំងអស់គឺមាន rational ក្នុងការជ្រើសរើសដើម្បីបំពេញអត្ថប្រយោជន៍ខ្លួនអតិបរិមាសមិទ្ធភាពអតិបរិមា Marginalism ការវិភាគសេដ្ឋកិច្ចត្រូវធ្វើដោយមើលជាបរិមាណតូចៗ marginal units ដូចជា marginal cost និង marginal utility ដើម្បីយល់ពីការផ្លាស់ប្តូរ ការបង្កើតតម្លៃតាមអត្ថប្រយោជន៍ Subjective Value Theory តម្លៃនៃទំនិញមិនកំណត់ដោយថ្លៃផលិតនោះទេតែដោយអត្ថប្រយោជន៍ឬតម្លៃដែលអតិថិជនផ្តល់ឱ្យ utility-based សេរីភាពទីផ្សារ Market Equilibrium តម្លៃនិងបរិមាណស្ថេរនៅពេលដែលផ្គត់ផ្គង់និងតម្រូវការស្មើគ្នា equilibrium ទីផ្សារអាចសម្របខ្លួនឯងដោយសេរីបែងចែកធនធានដោយប្រសិទ្ធភាព Efficient Resource Allocation តាមទ្រឹស្តីនេះទីផ្សារសេរីអាចបែងចែកធនធានយ៉ាងប្រសិទ្ធភាពតាមរយៈកម្លាំងផ្គត់ផ្គង់និងតម្រូវការអ្នកសេដ្ឋកិច្ចដ៏សំខាន់ៗមាន William Stanley Jevons បង្កើតទ្រឹស្តីអត្ថប្រយោជន៍អតិបរិមា (Marginal Utility Theory) Carl Menger បង្កើតទ្រឹស្តីតម្លៃផ្អែកលើអត្ថប្រយោជន៍ (Subjective Value Theory) Léon Walras បង្កើតទ្រឹស្តីសមីភាពទូទៅ (General Equilibrium Theory) Alfred Marshall ប្រើការវិភាគតម្លៃតាមតម្រូវការនិងផ្គត់ផ្គង់នាំមកនូវគំនិតថ្នាក់ដំបូងនៃជម្រើសអតិបរិមា។

ទ្រឹស្តីសេដ្ឋកិច្ច Keynesian (Keynesian Economics) គឺជាទ្រឹស្តីសេដ្ឋកិច្ចមួយដែលបានបង្កើតឡើងដោយសេដ្ឋកិច្ចសាស្ត្រអង់គ្លេសឈ្មោះ John Maynard Keynes នៅសតវត្សទី២០ដោយមានស្នាដៃដ៏ល្បីនាម The General Theory of Employment, Interest and Money (1936) ទ្រឹស្តីនេះបានកើតឡើង

ក្នុងបរិបទវិបត្តិសេដ្ឋកិច្ចធំឆ្នាំ១៩៣០ (Great Depression) ហើយបានផ្តល់នូវចម្លើយថ្មីនៃវិបត្តិសេដ្ឋកិច្ចដែលទ្រឹស្តីបុរាណមិនអាចដោះស្រាយបាន។គោលការណ៍សំខាន់ៗនៃទ្រឹស្តី Keynesian មានសេដ្ឋកិច្ចមិនសម្របខ្លួនឯងទេ (Market is not self-correcting) ផ្ទុយពី Classical Economics ដែលជឿលើសមត្ថភាពដោយខ្លួនឯង។ទ្រឹស្តី Keynesian ជឿថាទីផ្សារអាចដំណើរការមិនបានសមរម្យហើយអាចមានអត្រាការងារកើតឡើងបានតម្រូវការសរុបជាចំណុចស្នូល (Aggregate Demand = Key) កម្រិតផលិតកម្ម និងការងារគឺពឹងផ្អែកលើតម្រូវការសរុប (Aggregate Demand) ដោយសារតែការចំណាយសាជីវកម្មនេះជាការចំណាយរដ្ឋាភិបាល (Government Spending)ការប្រើប្រាស់របស់ប្រជាជន(Consumption)ការនាំចូលនិងនាំចេញ(Net Exports) ការជ្រៀតជ្រែករបស់រដ្ឋគឺចាំបាច់ (Government Intervention is necessary) ប្រសិនបើតម្រូវការសរុបធ្លាក់ចុះរដ្ឋគួរតែពង្រឹងសេដ្ឋកិច្ចតាមរយៈបង្កើនការចំណាយរដ្ឋបន្ថយពន្ធ និងបង្កើនការបញ្ចេញប្រាក់ (monetary & fiscal policy)ទឹកប្រាក់និងអត្រាការប្រាក់មានអនុភាពក្នុងការបង្កើនកំណើនអត្រាការប្រាក់ទាបអាចជំរុញការវិនិយោគនិងការចំណាយ ខណៈពេលអត្រាការប្រាក់ខ្ពស់អាចបន្ថយការចំណាយជំរុញកំណើនតាមរយៈ “ Multiplier Effect ” ការចំណាយបន្ថែមរបស់រដ្ឋមួយចំនួនអាចបង្កើតផលបូកសរុបដ៏ធំជាងមុន( ឧ.$1 ចំណាយអាចបង្កើតចំណូល$2 ឬ $3 )។

ទ្រឹស្តីសេដ្ឋកិច្ចម៉ូណេតារី(Monetarism) គឺជាទ្រឹស្តីសេដ្ឋកិច្ចមួយដែលផ្តោតលើតួនាទីសំខាន់នៃប្រាក់ក្នុងការបង្កើតស្ថិរភាពសេដ្ឋកិច្ចនិងការត្រួតពិនិត្យអតិផរណា វាបានកើតចេញជាការឆ្លើយតបទៅនឹងទ្រឹស្តី Keynesian Economics នៅដើមសតវត្សទី២០និងត្រូវបានលើកលែងដោយសេដ្ឋកិច្ចសាស្ត្រ Milton Friedman។ គោលការណ៍សំខាន់ៗនៃទ្រឹស្តីម៉ូណេតារីគឺប្រាក់ជាធាតុសំខាន់បំផុតក្នុងសេដ្ឋកិច្ច (Money matters most) ភាពរីកចម្រើននៃសេដ្ឋកិច្ចនិងអតិផរណាពឹងផ្អែកលើបរិមាណប្រាក់នៅក្នុងប្រទេស (money supply)ប្រសិនបើប្រាក់ចូលក្នុងប្រព័ន្ធច្រើនអតិផរណាអាចកើនឡើងការត្រួតពិនិត្យបរិមាណប្រាក់ (Control the money supply) រដ្ឋឬធនាគារជាតិនៃប្រទេសគួរតែគ្រប់គ្រងបរិមាណប្រាក់ដោយអារម្មណ៍ថេរៗ (fixed growth rule) ដើម្បីជៀសវាងការប្រែប្រួលតម្លៃនិងការអតិផរណា។ Inflation is always a monetary phenomenon ទ្រឹស្តីរបស់ Milton Friedman ពោលថា “Inflation is always and everywhere a monetary phenomenon” មានន័យថាអតិផរណាធ្វើឡើងពេលប្រាក់បញ្ចេញច្រើនជាងកំណើនផលិតកម្មពិតប្រាកដ real output ទីផ្សារមានសមត្ថភាពសម្របខ្លួនឯង (Markets are efficient) ដូចនឹង Classical economics។ ម៉ូណេតារីជឿថាទីផ្សារមានសមត្ថភាពសម្របខ្លួនខ្លួនឯងល្អជាងរដ្ឋជ្រៀតជ្រែក និងប្រើគោលនយោបាយប្រាក់ (Monetary Policy) ជាឧបករណ៍សំខាន់ទ្រឹស្តីនេះដោយមិនគាំទ្រការចំណាយរដ្ឋ (fiscal policy) ដូចជាទ្រឹស្តី Keynesian ទេតែផ្តោតទៅលើគោលនយោបាយប្រាក់ដើម្បីគ្រប់គ្រងសេដ្ឋកិច្ចសមីការសំខាន់មាន Quantity Theory of Money, MV = PQ តាមទ្រឹស្តីនេះប្រសិនបើ M កើនដោយឯងៗហើយ V និង Q មិនប្រែប្រួលនោះតម្លៃ P (អតិផរណា)នឹងកើនឡើង។ សេចក្តីសន្និដ្ឋាន Monetarism គឺជាចម្លើយទៅនឹងទ្រឹស្តី Keynesian ដោយដាក់សារសំខាន់លើប្រាក់បានផ្លាស់ប្តូរទិសដៅគោលនយោបាយសេដ្ឋកិច្ចនៅក្នុងសតវត្សទី២០និងមានឥទ្ធិពលខ្លាំងលើការអភិវឌ្ឍគោលនយោបាយធនាគារកណ្តាលរហូតដល់សព្វថ្ងៃ។

ទ្រឹស្តីសេដ្ឋកិច្ចស្ថាបនាសេរី (Institutional Economics) គឺជាទ្រឹស្តីសេដ្ឋកិច្ចមួយដែលផ្តោតលើតួនាទីនៃស្ថាប័នដូចជាច្បាប់គោលនយោបាយវប្បធម៌ក្រុម សីលធម៌ និងអង្គភាពសង្គមក្នុងការប៉ះពាល់ដល់

សេដ្ឋកិច្ចនិងអាកប្បកិរិយារបស់មនុស្ស។លក្ខណៈសំខាន់នៃ Institutional Economics ស្ថាប័នជាមូលដ្ឋាននៃសេដ្ឋកិច្ច(Institutions matter) ស្ថាប័ន គឺជាសំណុំច្បាប់ធនធានសង្គមដែលបង្កើត និងគ្រប់គ្រងអាកប្បកិរិយាសេដ្ឋកិច្ច និងអាកប្បកិរិយាបុគ្គលជាប់ពាក់ពន្ធ័នឹងបរិបទសង្គម (Context matters) ផ្ទុយពីទ្រឹស្តី Neoclassical economics ដែលជឿលើជម្រើសហុចផលរបស់បុគ្គលបែបនេះយល់ថាអាកប្បកិរិយាជាលទ្ធផលនៃបរិបទសង្គមនិងវប្បធម៌ប្រើវិធីសាស្រ្តផ្សំ (Interdisciplinary) បញ្ចូលចំណេះដឹងពីសង្គមវិទ្យា ចិត្តវិទ្យា ប្រវត្តិសាស្រ្ត និងច្បាប់ដើម្បីយល់សេដ្ឋកិច្ចសមត្ថភាព និងការប្រែប្រួលរបស់ស្ថាប័នអាចកែលម្អឬរាំងស្ទះដល់ការអភិវឌ្ឍសេដ្ឋកិច្ចបានពិភាក្សាអំពី path dependency និង historical institutionalism (អតីតកាលជារូបរាងនៃបច្ចុប្បន្ន) ចំណាត់ថ្នាក់ទ្រឹស្តីស្ថាបនាសេរី Old Institutional Economics (OIE) អ្នកបង្កើតមាន Thorstein Veblen, John R. Commons, Wesley Mitchell ទ្រឹស្តីនេះផ្តោតលើការប្រើវិធីសាស្រ្តសនិដ្ឋាន (qualitative, historical) អាកប្បកិរិយាសង្គម និងវប្បធម៌ New Institutional Economics (NIE) អ្នកបង្កើតមាន Douglass North, Oliver Williamson, Ronald Coase បញ្ចូលគំនិត Neoclassical economics ជាមួយការសិក្សាផ្តោតលើ Transaction costs, Property rights, Contract theory និង Path dependence។ សេចក្តីសន្និដ្ឋាន Institutional Economics ធ្វើឱ្យយើងយល់ថាសេដ្ឋកិច្ចជាផ្នែកមួយនៃសង្គមជួយពន្យល់ពីការរីកចម្រើនឬបរាជ័យជាច្រើនដោយមើលទៅលើស្ថាប័នជាចម្បង ទ្រឹស្តីនេះមានតួនាទីសំខាន់ខ្លាំងក្នុងការពិចារណាគោលនយោបាយសេដ្ឋកិច្ចការអភិវឌ្ឍប្រទេសនិងវិភាគបញ្ហាជាអន្តរជាតិ[15]។

[15] Stanford Encyclopedia. (2018-09-04). *"ទ្រឹស្តីសេដ្ឋកិច្ច"*. Retrieved from https://plato.stanford.edu/entries/economics/#ClaEco (Accessed February, 17 2025)

# ជំពូកទី៣
# ការរីកចម្រើននៃវិស័យហិរញ្ញវត្ថុនៅកម្ពុជា

## ៣.១ ស្ថានភាពទូទៅនៃការរីកចម្រើននៃវិស័យហិរញ្ញវត្ថុនៅកម្ពុជា

### ៣.១.១ ប្រវត្តិធនាគារជាតិនៃកម្ពុជា

ប្រទេសកម្ពុជាបានទទួលបានឯករាជ្យពីអាណានិគមនិយមបារាំងក្នុងឆ្នាំ១៩៥៣ ហើយនៅឆ្នាំបន្ទាប់ធនាគារជាតិនៃកម្ពុជា ក៏ត្រូវបានបង្កើតឡើងនៅខែធ្នូឆ្នាំ១៩៥៤ ដោយទទួលភារៈផ្តាច់មុខជាអ្នកបោះពុម្ពប្រាក់រៀលដែលជារូបិយវត្ថុជាតិ និងគ្រប់គ្រងប្រព័ន្ធធនាគារនៅកម្ពុជាមុនពេលទទួលបានឯករាជ្យ វិទ្យាស្ថានបោះប្រាក់ដែលមានទីតាំងនៅប្រទេសកម្ពុជា ហើយបានបោះពុម្ពរូបិយវត្ថុរួមគ្នាសម្រាប់បីប្រទេសនៅឥណ្ឌូចិន គឺប្រទេសកម្ពុជា ប្រទេសឡាវ និងវៀតណាម តែបន្ទាប់ពីទទួលបានឯករាជ្យធនាគារជាតិនៃកម្ពុជាបានបោះផ្សាយរូបិយវត្ថុជាតិ (ប្រាក់រៀល)១៩៥៤ ដើម្បីបំពេញអធិបតេយ្យភាពក្នុងការរក្សាស្ថិរភាពរូបិយវត្ថុ និងជួយកសាងអត្តសញ្ញាណជាតិ ក្នុងពេលនោះដែរប្រព័ន្ធធនាគារក្នុងស្រុកត្រូវបានកសាងឡើងវិញដែ លមានទាំងធនាគាររដ្ឋ និងឯកជនធ្វើប្រតិបត្តិការរួមគ្នា។ ក្នុងសម័យសង្គមរាស្ត្រនិយមនាដើមទសវត្សឆ្នាំ១៩៦០ ក្រោមការដឹកនាំរបស់ព្រះបាទនរោត្តមសីហនុ ព្រះរាជាណាចក្រកម្ពុជាមានការចម្រើនទូទាំងផ្ទៃប្រទេសនៅឆ្នាំ១៩៦៤ ប្រព័ន្ធធនាគារត្រូវបានធ្វើកំណែទម្រង់ដើម្បីឱ្យត្រូវតាមតម្រូវការសេដ្ឋកិច្ច និងការអភិវឌ្ឍនាសម័យនោះ ដោយបានប្រែក្លាយធនាគារជាតិនៃកម្ពុជាពីទម្រង់ស្ថាប័នពាក់កណ្តាលស្វ័យតទៅជាធនាគាររដ្ឋក្រោមទម្រង់ជាស្ថាប័នសាធារណៈដែលមានលក្ខណៈឧស្សាហកម្ម និងពាណិជ្ជកម្មទន្ទឹមនឹងនេះដែរធនាគារសាធារណៈ និងឯកជនជាច្រើនត្រូវបានបិទរាជរដ្ឋាភិបាលបានកសាងធនាគារ ដែលគ្រប់គ្រងដោយរដ្ឋមួយចំនួនដូចជា ធនាគារឥណទានសម្រាប់ការអភិវឌ្ឍន៍និងធនាគារកសិកម្មជនបទ។ នាថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ នៅពេលដែលរបបកម្ពុជាប្រជាធិបតេយ្យ (ខ្មែរក្រហម) បានកាន់អំណាចធនាគារជាតិនៃកម្ពុជាត្រូវបានបិទទ្វារអគារស្នាក់ការត្រូវបានកម្ទេចរូបិយវត្ថុជាតិត្រូវបានឈប់ប្រើប្រាស់ ហើយប្រព័ន្ធធនាគារត្រូវបានលុបបំបាត់ចោលទាំងស្រុងរហូតដល់ថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ របបខ្មែរក្រហមត្រូវបានគេផ្តួលរំលំ ហើយធនាគារជាតិនៃកម្ពុជាត្រូវបានបង្កើតឡើងវិញនៅថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៧៩ ក្នុងនាមជាធនាគារកណ្តាលរបស់ប្រទេស និងត្រូវបានប្តូរឈ្មោះជា "ធនាគារជាតិនៃប្រជាជនកម្ពុជា" ដោយក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា ទោះជាយ៉ាងនេះ ក្តីការកសាងធនាគារជាតិនៃកម្ពុជា និងប្រទេសជាតិបន្ទាប់ពីសង្គ្រាម ទើបនឹងបញ្ចប់ភ្លាមនេះមានការលំបាកយ៉ាងខ្លាំងជាមួយនឹងការខិតខំប្រឹងប្រែងជម្នះគ្រប់ឧបសគ្គ ដើម្បីកសាងប្រព័ន្ធធនាគារជាថ្មីឡើងវិញ ដោយផ្តើមចេញពីចំនុចសូន្យ លោកឯកឧត្តមជាចាន់តូទេស រដ្ឋមន្ត្រីនិងជាអភិបាលធនាគារជាតិនៃកម្ពុជា ជាអ្នកផ្តួចផ្តើមម្នាក់ក្នុងចំណោមអ្នកផ្តួចផ្តើមកសាងធនាគារជាតិ នៃកម្ពុជាដទៃទៀតរួមទាំងបុគ្គលិកមួយចំនួនតូច ដែលរស់រានមានជីវិតពីរបបខ្មែរក្រហមបានធ្វើការប្តេជ្ញាចិត្តយ៉ាងមុះមុតក្នុងការកសាងធនាគារជាតិនៃកម្ពុជាឡើងវិញ។ ទោះជាយ៉ាងនេះក្តី របបខ្មែរក្រហមបានបន្សល់ទុកនូវបញ្ហាប្រឈមជាច្រើន ដោយសារបញ្ញវ័ន្តជាច្រើនរូបត្រូវបានសម្លាប់ដោយពួកខ្មែរក្រហម និងខ្លះទៀតបានភៀសខ្លួនចេញពីប្រទេសបន្ទាប់ពីសង្គ្រាមចំនួនអ្នកចេះដឹង អ្នកជំនាញ និងអ្នកមានបទពិសោធន៍មានចំនួនតិចតួច អ្នកនៅរស់រានមានជីវិត និងមានសមត្ថភាពមួយចំនួនដែលនៅសេសសល់ក្នុងប្រទេសមានការភ័យ

ខ្លាច ក្នុងការធ្វើការដោយសារពួកគេគិតថារបបខ្មែរក្រហមអាចនឹងវិលត្រឡប់មកវិញ លើសពីនេះទៀត គឺកង្វះយ៉ាងធ្ងន់ធ្ងរនៃធនធានហិរញ្ញវត្ថុ ក្នុងពេលដែលសេដ្ឋកិច្ចនៅទន់ខ្សោយនៅឡើយ ហើយការផ្គត់ផ្គង់សាច់ប្រាក់ស្ទើរតែមិនមានសោះដោយសារតែគោលនយោបាយរបស់ខ្មែរក្រហម ចំណែកសកម្មភាពសេដ្ឋកិច្ចនៅតែត្រូវបានធ្វើឡើងជាលក្ខណៈដោះដូរទំនិញ និងទំនិញរឺឯប្រាក់ខែមន្ត្រីរាជការស៊ីវិលត្រូវបានទូទាត់ដោយប្រើអង្ករត្រីប្រេងជាដើមរហូតដល់ថ្ងៃទី២០ ខែមិនា ឆ្នាំ១៩៨០ ធនាគារនៃប្រជាជនកម្ពុជា បានបោះផ្សាយប្រាក់រៀលឡើងវិញ ដើម្បីសម្រួលដល់ការដោះដូរទំនិញ និងការទូទាត់ប្រាក់បៀវត្សមន្ត្រីរាជការស៊ីវិល។ បើទោះបីជា ជួបប្រទះបញ្ហាប្រឈមទាំងនេះជារៀងរាល់ថ្ងៃខែឆ្នាំក៏ដោយ ក៏មន្ត្រី-បុគ្គលិកនៃធនាគារជាតិនៃកម្ពុជានៅតែបន្តពុះពារឆ្ពោះទៅមុខជានិច្ចក្នុងការកសាងធនាគារជាតិឡើងវិញបន្តិចម្តងៗ នៅក្នុងអំឡុងទសវត្សឆ្នាំ១៩៨០ ធនាគារនៃប្រជាជនកម្ពុជាមានតួនាទីចម្បងៗបី គឺជាអាជ្ញាធររូបិយវត្ថុ ជារតនាគារជាតិ និងជាអ្នកផ្តល់សេវាកម្មធនាគារដែលរួមមានសេវាឥណទាន សេវាទទួលប្រាក់បញ្ញើ និងសេវាទូទាត់។ ចាប់តាំងពីអគារស្នាក់ការធនាគារជាតិនៃកម្ពុជា ត្រូវបានកម្ទេចដោយខ្មែរក្រហមទីស្នាក់ការកណ្តាលបណ្តោះអាសន្នរបស់ធនាគារត្រូវបានបើកនៅជាន់លើនៃធនាគារខ្មែរពាណិជ្ជ ធនាគារប្រជាជននៃកម្ពុជាបានបង្កើត រចនាសម្ព័ន្ធដឹកនាំក៏ដូចជាសកម្មភាពប្រតិបត្តិការជាច្រើនទៀត និងបានពង្រីកបណ្តាញសាខារបស់ខ្លួនដល់២៤ខេត្ត-ក្រុងទូទាំងប្រទេស។ ចាប់ពីឆ្នាំ១៩៨៩ មកប្រព័ន្ធធនាគារបានធ្វើកំណែទម្រង់បន្តិចម្តងៗ តាមរយៈការផ្លាស់ប្តូរធនាគារខេត្ត-ក្រុងចំនួន២០ ទៅជាធនាគារឯកទេសខេត្ត-ក្រុង ហើយធ្វើប្រតិបត្តិការជាមួយនឹងស្វ័យភាពហិរញ្ញវត្ថុ និងសេដ្ឋកិច្ចក្នុងដែនដីរបស់ពួកគេក្នុងនាមជាអាជ្ញាធររូបិយវត្ថុធនាគារនៃប្រជាជនកម្ពុជា បានត្រួតពិនិត្យលើដំណើរការរបស់ធនាគារពាណិជ្ជទាំងនោះ អគារស្នាក់ការធនាគារជាតិនៃកម្ពុជាត្រូវបានកសាងឡើងវិញនៅក្នុងឆ្នាំ១៩៩០។ នៅឆ្នាំ១៩៩១ធនាគារពាណិជ្ជដំបូងគេ(ធនាគារពាណិជ្ជកម្ពុជា"CCB")ត្រូវបានបង្កើតឡើងក្រោមទម្រង់ជាធនាគារវិនិយោគរួមគ្នារបស់រដ្ឋ ដើម្បីទាក់ទាញវិនិយោគិននិងបម្រើឱ្យសកម្មភាពអាជ្ញាធរអ៊ុនតាក់ប្រចាំនៅកម្ពុជា សន្និសញ្ញាសន្តិភាពទីក្រុងប៉ារីសថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ បានផ្លាស់ប្តូររបបសេដ្ឋកិច្ចកម្ពុជាពីសេដ្ឋកិច្ចផែនការមកជាសេដ្ឋកិច្ចទីផ្សារសេរីនៅថ្ងៃទី៣០ខែមករាឆ្នាំ១៩៩២រដ្ឋសភាជាតិបានអនុម័តច្បាប់ស្តីពីការប្តូរឈ្មោះ ព្រមទាំងកាតព្វកិច្ចរបស់ធនាគារជាតិនៃកម្ពុជាពី "ធនាគារនៃប្រជាជនកម្ពុជា"មកជា "ធនាគារជាតិនៃកម្ពុជា" វិញដែលត្រូវបានប្រកាសឱ្យប្រើដោយក្រុមប្រឹក្សារដ្ឋនាថ្ងៃទី០៨ ខែមិនា ឆ្នាំ១៩៩២។ ធនាគារជាតិនៃកម្ពុជាបានចងក្រង និងរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុពីឆ្នាំ២០០១ដល់២០១០ ឯកសារនេះមានមុខងារជាមូលដ្ឋានគ្រឹះសម្រាប់យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ដើម្បីបង្កើនទំនុកចិត្តរបស់សាធារណជនចំពោះប្រព័ន្ធធនាគារ និងវិធីសាស្ត្រដែលកម្ពុជាអាចធ្វើសមាហរណកម្មទៅក្នុងប្រព័ន្ធហិរញ្ញវត្ថុសកលក្នុងនាមជាធនាគារកណ្តាលរបស់ជាតិ។ ធនាគារជាតិនៃកម្ពុជាបានធ្វើការកែលម្អអគារស្នាក់ការនៅឆ្នាំ ២០០៣ ដើម្បីលើកមុខមាត់និងកិត្យានុភាពរបស់ខ្លួនប្រព័ន្ធធនាគារនៅកម្ពុជាមានការរីកចម្រើនគួរឱ្យកត់សំគាល់ចាប់តាំងពីពាក់កណ្តាលទសវត្សឆ្នាំ១៩៩០ នៅពេលដែលច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជាច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុច្បាប់និងបទប្បញ្ញត្តិនានាក៏ដូចជាគន្លឹះនៃការធ្វើកំណែទម្រង់វិស័យធនាគារសំខាន់ផ្សេងទៀតត្រូវបានអនុវត្ត។ បច្ចុប្បន្នប្រព័ន្ធធនាគារនៅកម្ពុជារួមមានធនាគារពាណិជ្ជចំនួន៣៦ ធនាគារឯកទេសចំនួន១១ តំណាងធនាគារបរទេសចំនួន៧ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន៣៩ ក្នុងនោះរួមបញ្ចូលទាំងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់

បញ្ចើចំនួន០៧ប្រតិបត្តិករឥណទានជនបទចំនួន៣៨ ក្រុមហ៊ុនជួលចំនួន៦ ការិយាល័យឥណទានចំនួន១ និងអាជីវករប្តូរប្រាក់ចំនួន១៧៧០ ព្រមទាំងដំណើរការតតីយភាគីចំនួន៦។ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុកំពុងបន្តពង្រីកបណ្តាញប្រតិបត្តិការរបស់ខ្លួន តាមរយៈការបើកសាខា និងការិយាល័យតំណាងជាច្រើនកន្លែងក្នុងរាជធានីខេត្ត និងដំឡើងម៉ាស៊ីនដកប្រាក់ដោយស្វ័យប្រវត្តិ (អេធីអឹម) បន្ថែមលើការផ្តល់សេវាទូទាត់អេឡិចត្រូនិក ។

### ៣.១.២ ទស្សនវិស័យ ឬបេសកកម្មរបស់វិស័យហិរញ្ញវត្ថុ

#### ក ទស្សនវិស័យ

វិស័យហិរញ្ញវត្ថុមានទស្សនៈផ្តោតលើការចូលរួមទូលំទូលាយ និងគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ចយ៉ាងទូលំទូលាយដើម្បីកាត់បន្ថយភាពក្រីករជាក់ស្តែងយុទ្ធសាស្ត្រ Financial Sector Development Strategy ២០២១-២០៣០ ត្រូវបានរចនាឡើងដើម្បីជួយឱ្យវិស័យហិរញ្ញវត្ថុទទួលបានកម្រិតសមិទ្ធផលខ្ពស់ និងអាចគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ចដោយសុទិដ្ឋិនិយម និងកាត់បន្ថយភាពក្រីក្រ ។ ក្នុងនោះយុទ្ធសាស្ត្របច្ចេកវិទ្យាហិរញ្ញវត្ថុ ២០២៣-២០២៨ បានដាក់ក្រុមទស្សនៈបែបវែងថា «ការអភិវឌ្ឍ FinTech ដោយផ្អែកលើការកែលម្អដំណើរការហិរញ្ញវត្ថុ ការទប់ស្កាត់ស្ថេរភាព និងការជម្រុញច្នៃប្រឌិតផ្នែកហិរញ្ញវត្ថុដើម្បីស្រង់យកនៅអត្ថប្រយោជន៍ខ្ពស់ពីឌីជីថលក្នុងវិស័យហិរញ្ញវត្ថុ និងផ្តល់ឱកាសដល់សកម្មភាគីទាំងអស់ ដើម្បីរួមចំណែកលើកម្ពស់ការលូតលាស់សេដ្ឋកិច្ចឌីជីថល និងសង្គមដ៏រុងរឿង»។

#### ខ បេសកកម្ម

វិស័យហិរញ្ញវត្ថុមានបេសកកម្មសំខាន់ ក្នុងការធ្វើឱ្យប្រជាពលរដ្ឋទូទាំងប្រទេសអាចចូលប្រើប្រាស់សេវាហិរញ្ញវត្ថុបានយ៉ាងទូលំទូលាយមានប្រសិទ្ធភាព ដើម្បីលើកតម្កើងកម្រិតជីវិតសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រ។ ចំពោះយុទ្ធសាស្ត្រ FinTech ២០២៣-២០២៨ មានបេសកកម្មអភិវឌ្ឍប្រព័ន្ធ FinTech ដែលមានជីវិតតាមរយៈការកែលម្អនយោបាយគាំទ្រឧបករណ៍ឌីជីថល ដើម្បីជំរុញការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលការច្នៃប្រឌិតដោយមានគោលបំណងបង្កើនការចូលដំណើរការនិងភាពទុកចិត្តក្នុងសេវាហិរញ្ញវត្ថុនិងធានាគុណភាពជីវិតសម្រាប់អ្នកប្រើប្រាស់ក្នុងសម័យឌីជីថល។

### ៣.១.៣ ប្រភេទនៃវិស័យហិរញ្ញវត្ថុ

#### ក វិស័យធនាគារ

វិស័យធនាគារជាផ្នែកសំខាន់នៃប្រព័ន្ធហិរញ្ញវត្ថុជាតិដែលមានធនាគារជាតិ ជាស្ថាប័នឯកភាពគ្រប់គ្រងវិស័យធនាគារនៅកម្ពុជាមានភារកិច្ចសំខាន់ៗដូចជា បង្កើតអនុវត្តនយោបាយរូបិយប័ណ្ណត្រួតពិនិត្យ និងគ្រប់គ្រងស្ថាប័នធនាគាររក្សាស្ថេរភាពនៃប្រព័ន្ធហិរញ្ញវត្ថុ។ធនាគារជាតិនៃកម្ពុជា(NBC)បានដាក់ចេញនូវច្បាប់ថាគ្រឹះស្ថានធនាគារទាំងអស់ត្រូវស្នើសុំអាជ្ញាបណ្ណ និងស្ថិតក្រោមការត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា ដើម្បីធានាស្ថេរភាព(អនុលោមតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ)ដោយមានច្បាប់បន្ថែមដូចជាច្បាប់ប្រឆាំងនឹងការបោកប្រាស់ឧក្រិដ្ឋកម្មហិរញ្ញវត្ថុលើកលែងការខាតបង់នៅធនាគារ។បន្ថែមពីនេះធនាគារជាផ្នែកមួយសំខាន់នៃប្រព័ន្ធហិរញ្ញវត្ថុបានកាន់កាប់ភាគរយចំនួន82.2% នៃទ្រព្យសរុបក្នុងប្រព័ន្ធហិរញ្ញវត្ថុ។ការផ្តល់ឥណទានដល់អាជីវកម្មនិងគ្រួសារ ដើម្បីលើកកម្ពស់សកម្មភាពសេដ្ឋកិច្ចនិងការវិនិយោគដោយឥណទានសរុបមានទ្រព្យប័ណ្ណសរុបជិត ១៦៣% នៃGDP នៅឆ្នាំ២០២៣។នាយកដ្ឋានធនាគារជាតិ

(NBC)ជាអាជ្ញាធរមេត្រួតពិនិត្យប្រព័ន្ធទូទាត់និងបោះចេញប្រាក់រៀល។ ពេលថ្មីៗនេះប្រព័ន្ធទូទាត់អេឡិចត្រូនិចនិងQRបានគាំទ្រដល់ធនាគារសម្រាប់ការផ្តល់សេវាទាន់សម័យដល់ប្រជាជន។ ការចូលរួមប្រជាជនក្នុងប្រព័ន្ធហិរញ្ញវត្ថុកើនឡើងយ៉ាងគួរឱ្យចាប់អារម្មណ៍ព័ត៌មានមួយពី UNCDF បង្ហាញថាភាគរយប្រជាជនដែលប្រើប្រាស់សេវាហិរញ្ញវត្ថុបានកើនពី ៥៩% (ឆ្នាំ២០១៥) ដល់ ៦៧% (ឆ្នាំ២០២១) និងនៅក្នុង World Bank Doing Business (២០២០) កម្ពុជានៅលំដាប់ទី២៥នៃ១៩០ប្រទេសក្នុងវិស័យសេវាឥណទាន គេសង្កេតឃើញថាវិស័យធនាគារនិងអង្គភាពហិរញ្ញវត្ថុផ្សេងទៀត(ធនាគារពិសេសនិងមីក្រូហិរញ្ញវត្ថុ)បានជួយធានាការចូលរួមសង្គមធំជាងមុន និងលើកកម្ពស់ស្ថេរភាពហិរញ្ញវត្ថុសម្រាប់ប្រជាជនទូលំទូលាយនៅចុងឆ្នាំ២០២០ កម្ពុជាមាន ៥១ធនាគារពាណិជ្ជកម្ម ១២ធនាគារពិសេស ៧៥គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ ៦គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលទទួលប្រាក់បញ្ញើ និង២៤៥កម្ចីជនបទ។ ក្នុងឆ្នាំ២០២៣ទ្រព្យសម្បត្តិសរុបនៃវិស័យធនាគារកើនដល់ប្រមាណ $77.4 ពាន់លាន (243% នៃ GDP) ប្រៀបធៀបទៅនឹង $67.9 ពាន់លានឆ្នាំ ២០២២ ចុងឆ្នាំ២០២៣ ឥណទានសរុបនៅកម្ពុជាមានតម្លៃប្រមាណ $57.6 ពាន់លាន (ស្មើ 163% នៃ GDP) និងប្រាក់ដាក់សរុប $47.9 ពាន់លាន (ស្មើ 144% នៃ GDP) នេះមានន័យថាកំណើនឥណទានទួលបាន 4.8% ប៉ុណ្ណោះខណៈដែលប្រាក់បញ្ញើកើន 13.1% ទៅវិញភាគរយប្រជាជនចូលដំណើរការសេវាហិរញ្ញវត្ថុបានកើនឡើងយ៉ាងខ្លាំងដោយគេគណនាឃើញថា កំពុងមានប្រជាជនប្រមាណ67%បានប្រើប្រាស់សេវាហិរញ្ញវត្ថុក្នុងឆ្នាំ២០២១ ទន្ទឹមនឹងនេះធនាគារទាំងអស់នៅកម្ពុជាកំពុងពង្រឹងធនធាន(ផ្តល់ឥណទាន)។ ជាការពិតណាស់ស្ថាប័នពាក់ព័ន្ធនិងប្រភេទធនាគារត្រូវបានគេបែងចែកជាច្រើនរួមមានធនាគារពិសេសមានគោលបំណងផ្តល់ជំនួយហិរញ្ញវត្ថុខាងតម្រូវការផ្សេងៗ (ឧ. កសិកម្មឬអភិវឌ្ឍជនបទ) មាន ១២ធនាគារពិសេស (រួមទាំងធនាគារ Rural Development Bank)។គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជាស្ថាប័នឧបត្ថម្ភឥណទានតូចៗទៅកាន់ក្រុមគ្រួសារនិងសហគមន៍សេដ្ឋកិច្ចមានចំនួន៧៥គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ និង៦គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលទទួលប្រាក់បញ្ញើ។ស្ថាប័នឱ្យកម្ចីជនបទមានភាពសារៈសំខាន់ក្នុងការអភិវឌ្ឍជនបទដោយការផ្តល់ឥណទានឱ្យសហគមន៍ជនបទមាន ២៤៥ស្ថាប័នឱ្យកម្ចីជនបទនៅចុងឆ្នាំ២០២០។សេវាហិរញ្ញវត្ថុផ្សេងទៀតរួមមានក្រុមហ៊ុនជួលសម្ភារៈ (leasing) ក្រុមហ៊ុនដំណើរការធ្វើប្រតិបត្តិការប្រាក់ផ្ទាល់ជីវៈ (third-party payment processors) និងស្ថាប័នផ្សេងៗដូចជា Credit Bureau Cambodia ស្ថាប័នទាំងនេះស្ថិតក្រោមការត្រួតពិនិត្យដោយ NBC យោងតាមរបាយការណ៍បានឱ្យឃើញថាធនាគារពាណិជ្ជជាប្រភពដ៏ធំក្នុងការអនុវត្តសេវាទូទាត់ដោយទទួលប្រាក់បញ្ញើពីសាធារណជន និងគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធទូទាត់ដូចជាម៉ាស៊ីន ATM មានចំណូលចម្បងសម្រាប់ផ្តល់ឥណទាន និងទទួលប្រាក់ដាក់ពីសាធារណៈនិងឯកជននៅចុងឆ្នាំ២០២០មានចំនួន៥១ធនាគារពាណិជ្ជកម្ម(រួមទាំងធនាគារពីបរទេសនិងក្នុងស្រុក)។ ប្រាក់បញ្ញើ គឺជាប្រាក់សន្សំរបស់ប្រជាពលរដ្ឋផ្តល់មូលដ្ឋានសំខាន់ សម្រាប់ប្រតិបត្តិការទូទាត់ក្រៅសាច់ប្រាក់ (electronic payment) ព្រមគ្នានេះធនាគារយកទំនួលខុសត្រូវក្នុងការផ្តល់ឥណទានដល់សហគ្រាសប្រជាជនថែមទាំងពង្រឹងបច្ចេកវិទ្យា និងពង្រីកសេវាកម្មបន្ថែមដើម្បីគាំទ្រកំណើនសេដ្ឋកិច្ចជាតិនិងការងារ។

### ខ វិស័យមូលបត្រ (Securities Sector)

ទីផ្សារមូលបត្រកម្ពុជា ស្ថិតនៅក្នុងដំណាក់កាលដើមនៃការអភិវឌ្ឍន៍ រដ្ឋបានទទួលប្រាក់ប្រមូលពីការលក់មូលបត្រ និងកម្ចីដើម្បីនាំចូលថវិកាសម្រាប់គម្រោងសាធារណៈតាមការវាយតម្លៃថ្មីៗបានឱ្យឃើញថា ទីផ្សារមូលបត្រនៃប្រទេសកម្ពុជាបានឈានដល់ត្រឹមតែប្រមាណ០,៣% នៃ GDP នៅឆ្នាំ ២០២៤តែប៉ុណ្ណោះ ទោះជាយ៉ាងណា អាជ្ញាធរជាតិបានដាក់ដំណើរការមុខងារច្រើនក្នុងការលើកកម្ពស់វិស័យមូលបត្រច្បាប់កំណត់ឡើងវិញ សម្រាប់មូលបត្រឯកជនត្រូវបានចូលប្រើនៅឆ្នាំ២០១៧ មានបទបញ្ញាថ្មីៗរួមទាំងស្តីពីការបញ្ចេញឯកសារភាគីឯកជនត្រូវបានចុះបញ្ជីនៅឆ្នាំ២០១៨ (ក្រុមហ៊ុន Hattha Kaksekar) រហូតមកដល់ឆ្នាំ២០២៤មានមូលបត្រឯកជនប្រមាណជាង១០ប្រភេទត្រូវបានចេញលក់ក្នុងផ្សារ Cambodia Securities Exchange (CSX)។ រដ្ឋាភិបាលក៏ចាប់ផ្តើមចេញមូលបត្រក្នុងឆ្នាំ២០២២ដើម្បីសម្រេចគោលដៅទីផ្សារហិរញ្ញវត្ថុ ហើយភាគីរដ្ឋបានប្រមូលប្រាក់បានប្រមាណ១១៧ លានដុល្លារអាមេរិកដល់ចុងទីបីឆ្នាំ២០២៤ វិស័យមូលបត្រជាទូទៅត្រូវបានគេដាក់ជាឧបករណ៍មួយ សម្រាប់បង្កើនជម្រើសការវិនិយោគ ការបោះផ្សាយមូលបត្រអនុញ្ញាតឱ្យក្រុមហ៊ុនស្វែងរកប្រភពថវិកា ដោយមិនបាត់បង់ភាគហ៊ុនផ្ទុយមកវិញ ទទួលបានតម្លៃស្តង់ដារល្អនិងផ្តល់ជម្រើសវិនិយោគថ្មីៗដល់អ្នកវិនិយោគ។ Securities and Exchange Regulator of Cambodia អង្គភាពត្រួតពិនិត្យនិងគ្រប់គ្រងទីផ្សារមានអាជ្ញាធរជាអង្គភាពមានសិទ្ធិគ្រប់គ្រងទីផ្សារមូលបត្រ និងភាគហ៊ុនSERC បានបង្កើតឡើងក្រោមច្បាប់ ២០០៧ ដើម្បីមើលឃើញថាការបញ្ចេញទិញលក់សារពើភ័ណ្ឌធ្វើឡើងយ៉ាងត្រឹមត្រូវ និងរលូនដោយមានគោលដៅជួយប្រមូលទុនសម្រាប់អភិវឌ្ឍន៍សេដ្ឋកិច្ចនៃប្រទេស។ SERC បានចេញផ្សាយបទបញ្ញាបន្ថែមជាច្រើនសម្រាប់ការបញ្ចេញមូលបត្រសាធារណៈ និងការអនុញ្ញាតអាជីវកម្មទាក់ទងដូចជាការកំណត់តំណាងអតិថិជនមូលបត្រ និងការអនុម័តក្រុមហ៊ុនឥណទាន។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(MEF) ជាអាជ្ញាធរដឹកនាំទូទៅចំពោះការចេញមូលបត្ររដ្ឋ (government bonds) និងគ្រប់គ្រងទុនសាធារណៈ(MEF) នឹងដាក់សេចក្តីសម្រេចថាចាំបាច់សម្រាប់កាបញ្ចេញbond និងបង្កើតច្បាប់ក្រមដើម្បីជំរុញទីផ្សារហិរញ្ញវត្ថុ ជាឧទាហរណ៍MEFបានប្រមូលប្រាក់ប្រមាណ ២៨ពាន់លានរៀលប្រមាណ៦.៨លានដុល្លារតាមរយៈការបញ្ចេញមូលបត្ររដ្ឋដោយប្រើវេទិកា online របស់ធនាគារជាតិ។ ព័ត៌មានថ្មីៗ បានបង្ហាញថាក្រសួងនេះ មានគម្រោងបោះចេញនូវមូលបត្ររដ្ឋប្រមាណ១០០ លានដុល្លារនៅឆ្នាំ២០២៤ ដើម្បីគាំទ្រគម្រោងវិនិយោគសាធារណៈ ធនាគារជាតិនៃកម្ពុជា(NBC) ជាអង្គភាពដឹកនាំប្រព័ន្ធធនាគារ ហើយជាក្រុមហ៊ុនផ្សាយបញ្ចេញមូលបត្ររដ្ឋជាផ្លូវការតាមវេទិកា NBCP (NBC Platform) ធនាគារជាតិនៃកម្ពុជាគ្រប់គ្រងការអនុម័តអនុវត្តលើធនាគារ និងមូលបត្រតាមរយៈបទបញ្ញាថ្មីៗតម្រូវឱ្យធនាគារជានាចេញសារពើភ័ណ្ឌនៅលើផ្សារហ៊ុន ដោយទទួលការអនុម័តពីធនាគារជាតិនៃកម្ពុជាជាមុន ក្រៅពីនេះធនាគារជាតិនៃកម្ពុជាមានវិសាលភាពទូទៅក្នុងការត្រួតពិនិត្យវិស័យធនាគារ និងធានាបន្ទុកក្រាល។ប្រភេទនៃមូលបត្រមាន២ធំៗ គឺមូលបត្ររាជរដ្ឋបាល (Sovereign Bonds) ជាមូលបត្រដែលចេញដោយរដ្ឋាភិបាលកម្ពុជា បានចាប់ផ្តើមបញ្ចេញមូលបត្ររដ្ឋជាលើកដំបូងក្នុងខែកញ្ញា២០២២ ដើម្បីចូលទុនសម្រាប់គម្រោងសាធារណៈនានា មូលបត្រទាំងនេះ ភាគច្រើនមានអាយុកាលខ្លីក្រៅពីទីផ្សារអន្តរជាតិដែលណែនាំឱ្យបញ្ចេញខ្លីក្រោម៣ឆ្នាំ មូលបត្រឯកជន (Corporate Bonds) ចេញដោយសហគ្រាសឯកជនឬស្ថាប័នផ្ទាល់ខ្លួនត្រូវបានបញ្ចេញឡើងក្នុងឆ្នាំ២០១៨ ដោយ Hattha Kaksekar សម្រាប់តម្លៃ$30លាន បន្ទាប់មក

មានសហគ្រាសឯកជនផ្សេងទៀតដូចជា Telcotech (Royal Group), LOLC, Wing, Amret, Golden Tree រួមទាំងដៃគូធនាគារកម្ពុជានានា បានចូលរួមបញ្ចេញមូលបត្រ។ មូលបត្រឯកជនទាំងនេះ ចេញនៅក្នុងទ្រង់ទ្រាយខុសៗគ្នាមាន (guaranteed bond, plain bond) ដោយ CGCC ឬអង្គការធានារ៉ាប់រងអន្តរជាតិ (CGIF, GuarantCo) បណ្ណាំភ្ជាប់អត្រាប្តូរប្រាក់ (FX-linked bond)ដែលអាចជាប់នឹងអត្រាប្តូរទឹកប្រាក់ដុល្លារ ឬរៀលក៏ដូចជា Social/Sustainability Bondsនិង GreenBonds ដែលទើបត្រូវបានដំណើរការថ្មីៗប្រភេទទាំងនេះបានផ្តល់ជាជម្រើសសម្រាប់ការវិនិយោគនិងជួយលើកស្ទួយគម្រោងលើកដំបូងនៃឧស្សាហកម្មជាតិ សេវាកម្មនិងប្រព័ន្ធផ្សារមានផ្សារមូលបត្រកម្ពុជា (Cambodia Securities Exchange – CSX) ផ្សារ CSX ជាផ្សារដែលបានអនុញ្ញាតដោយអាជ្ញាធរ SERC សម្រាប់ការចុះបញ្ជីនិងជួញដូរមូលបត្រទាំងអស់។ CSX មានអាជ្ញាប័ណ្ណបំពេញទីផ្សារហ៊ុននិងសេវាកម្មសងបង់និងកក់ប្រាក់ (clearing & depository) ព្រឹត្តិការណ៍ចុះបញ្ជីមូលបត្រជាទីផ្សារដំបូងត្រូវធ្វើតាមសម្គាល់ និងលក្ខខណ្ឌរបស់CSXដើម្បីធានាសុវត្ថិភាពអត្តសញ្ញាណអ្នកចុះបញ្ជីនិងការផ្សព្វផ្សាយព័ត៌មាន។ ក្រុមហ៊ុនជួញដូរនិងភ្នាក់ងារ (Brokerages & Dealers) ក្រុមហ៊ុនដូចជា SBI Royal Securities, Phnom Penh Securities, RHB, Camana និងក្រុមហ៊ុន Royal Group Securities ជាអង្គភាពសំខាន់សម្រាប់ការប្រែប្រួល និងផ្តល់ព្រឹត្តិប័ត្រសម្រាប់មូលបត្រជូនអតិថិជនពួកគេបញ្ចេញមូលបត្រតាមរយៈ underwriting & advisory សេវាកម្មគាំទ្រផ្សេងៗទៀតមាន អង្គការធានារ៉ាប់រងដូចជាស្ថាប័នធានារ៉ាប់រងឥណទានកម្ពុជា(CGCC)ដែលជាមធ្យោបាយធានាបំណុលឯកជនដើម្បីគាំទ្រការចេញមូលបត្រមានអង្គការអន្តរជាតិដូចជាGuarantCo និង Credit Guarantee Investment Facility (CGIF) ព្រមទាំងមានកម្មវិធីលើកស្ទួយមូលបត្រ Green bonds ដែលសហការជាមួយ UN ESCAP និងអង្គការអភិវឌ្ឍន៍ផ្សេងៗ ជដើម្បីលើកកម្ពស់ការបញ្ចេញបណ្ណាំបៃតង និងសង្គមថ្មីៗក្នុងទីផ្សារ។ ប្រព័ន្ធផ្សារ (Infrastructure) អ្នកវិនិយោគអាចប្រើប្រាស់បណ្តាៗរហូតដល់NBCP (NBC Platform) សម្រាប់ចូលទិញមូលបត្ររដ្ឋ CSX បានបង្កើតប្រព័ន្ធធានាសងប្រាក់ក្នុងរយៈពេលដដែល (clearing settlement) សេវាកម្មវិនិច្ឆ័យអត្រា (Credit Rating) ក៏ត្រូវបានអនុញ្ញាតដោយ SERC ដើម្បីជួយផ្តល់តម្លៃការវិនិយោគសរុបទៅវិញ។ ទីផ្សារមូលបត្រកម្ពុជាត្រូវការសហការនិងកំណត់គោលដៅច្បាស់ពីរដ្ឋាភិបាល និងសេក្តីគ្រប់គ្រងគួរឱ្យទុកចិត្តដើម្បីធានាការអភិវឌ្ឍន៍យុទ្ធសាស្ត្ររបស់វិស័យនេះបានជោគជ័យ។

**គ វិស័យធានារ៉ាប់រង (Insurance Sector)**

វិស័យធានារ៉ាប់រង ជាវិស័យសេដ្ឋកិច្ចដែលផ្តល់សេវាការពារហានិភ័យតាមរយៈការបង់ប្រាក់ធានារ៉ាប់រង (insurance premiums) ដោយបង្ក្រាបបញ្ហា ឬការខាតបង់ដែលអាចកើតឡើងនៅពេលអនាគតក្រុមហ៊ុនធានារ៉ាប់រងនឹងផ្តល់សំណង(compensation)ជូនអតិថិជនពេលកើតមានហានិភ័យដូចបានកំណត់ក្នុងកិច្ចសន្យា (policy contract) មិនតែប៉ុណ្ណោះវិស័យធានារ៉ាប់រងត្រូវបានគេទទួលស្គាល់ថាជាផ្នែកសំខាន់នៃសន្តិសុខសង្គម និងការអភិវឌ្ឍសេដ្ឋកិច្ចមានតួនាទីផ្តល់ការពារហានិភ័យ (risk protection) ដល់សង្គមនិងសេដ្ឋកិច្ច។ ក្រុមហ៊ុនធានារ៉ាប់រងយកប្រាក់ដែលប្រមូលបានពីការលក់គម្រោងធានា (premiums) ទុកហើយផ្តល់សំណង់ទៅវិញនៅពេលមានហានិភ័យកើតឡើង ដោយហេតុនេះ វាបានប្រើប្រាស់ធនធានដើម្បីរក្សាស្ថេរភាពហិរញ្ញវត្ថុនិងកាត់បន្ថយ volatility។ លោកប៊ូច័ន្ទកីរូអគ្គនាយកនិយ័តករធានារ៉ាប់រងកម្ពុជាបានបញ្ជាក់ថាវិស័យធានារ៉ាប់រងបានដើរតួនាទីជា social protection ហើយរដ្ឋាភិបាលក៏បានរួមចំណែករួម

ជា Pentagonal Strategy សម្រាប់កម្ពុជាស្តង់ដារស្ថាប័នហិរញ្ញវត្ថុមិនមែនធនាគារជាឧបករណ៍សំខាន់នៃសេដ្ឋកិច្ចជាតិ។ ក្រៅពីនេះឯកឧត្តម អូន ប៉ណ្ណេត ជាអនុប្រធានរដ្ឋមន្ត្រីអភិបាលការសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ជាអគ្គនាយកអ.ស.ហ.ថែមទៀត) មើលឃើញអត្រាកំណើនប្រមាណ ២០% ជារៀងរាល់ឆ្នាំក្នុងរយៈដំបូង ១០ឆ្នាំចុងក្រោយ និងសរុបទ្រព្យសកម្មសរុបរបស់វិស័យនេះមានUS$1.2ពាន់លានក្នុងឆ្នាំ២០២៤ ទិន្នន័យទាំងនេះបញ្ជាក់ថា វិស័យធានារ៉ាប់រងកំពុងកាន់កាប់តួនាទីសំខាន់ក្នុងការឆ្លងផុតហានិភ័យ និងជំរុញការរីកចម្រើនរបស់សេដ្ឋកិច្ចជាតិ វិស័យធានារ៉ាប់រងដំណើរការជាមួយអង្គភាពសាធារណៈ និងឯកជនជាច្រើនរួមមានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ(MEF) ជាអាជ្ញាធរនាំមុខក្នុងគោលនយោបាយហិរញ្ញវត្ថុដឹកនាំគ្នា ជាមួយស្ថាប័នមិនមែនធនាគារដើម្បីរៀបការវិវឌ្ឍសេដ្ឋកិច្ច និងវិស័យហិរញ្ញវត្ថុរួម។ អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ(អ.ស.ហ.) ជាអង្គភាពថ្មីមួយស្ថិតនៅក្រោម MEF ដែលមានឯកឧត្តម អូន ប៉ណ្ណេត ជាអគ្គនាយក (ក៏គឺជាអនុប្រធានរដ្ឋមន្ត្រីសេដ្ឋកិច្ច) អ.ស.ហ. ត្រូវបានទទួលខុសត្រូវលើការត្រួតពិនិត្យវិស័យធានារ៉ាប់រងដើម្បីធានាប្រសិទ្ធភាពនិងសុវត្ថិភាព។និយ័តករធានារ៉ាប់រងកម្ពុជា (IRC) ជាអាជ្ញាធរត្រួតពិនិត្យនិងអនុញ្ញាតឱ្យស្ថាប័នធានារ៉ាប់រងដំណើរការលោក ប៊ូ ច័ន្ទភីរូ ជាអគ្គនាយកនៃ IRC និងបន្តស្ថាបនាជាមួយសមាគមនិងអាជ្ញាធរផ្សេងៗគាត់បានរៀបចំសិក្ខាសាលាអំពីស្តង់ដា IFRS17 សម្រាប់វិស័យធានារ៉ាប់រងដើម្បីគាំទ្រការបំពេញបែបបទគណនេយ្យស្តង់ដារអន្តរជាតិ។ សមាគមធានារ៉ាប់រងកម្ពុជា(IAC)ជាពាណិជ្ជកម្មមិនរកប្រាក់ចំណេញ ដ៏ចម្បងសម្រាប់ឧស្សាហកម្មធានារ៉ាប់រង IAC តំណាងឱ្យក្រុមហ៊ុនធានារ៉ាប់រងជាសមាជិកនានា និងបំពេញនាទីក្នុងការពង្រឹងភាពរីកចម្រើនរួមនៃវិស័យនេះ សមាគមនេះ មានកិច្ចសហប្រតិបត្តិការជាមួយ IRC ដើម្បីចែករំលែកព័ត៌មាននិងបង្កើនការយល់ដឹងរបស់សាធារណៈ។ ក្រុមហ៊ុនធានារ៉ាប់រងឯកជនរួមមានក្រុមហ៊ុនជាតិនិងបរទេសដូចជា AIA, Prum, Manulife, SGI, FWD, Forte, Prudential លទ្ធផលនិងក្រុមហ៊ុនធានារបស់ពួកគេដើម្បីផ្តល់នូវសេវាធានារួមជាពិសេស។ វិស័យធានារ៉ាប់រងកម្ពុជាផ្តល់សេវាបានជាច្រើនប្រភេទដើម្បីគ្របដណ្តប់ហានិភ័យនានាមានធានារ៉ាប់រងជីវិត (Life Insurance) គឺជាការធានាសុវត្ថិភាពផ្នែកហិរញ្ញវត្ថុសម្រាប់គ្រួសាររបស់អ្នកនៅពេលដែលអ្នកបាត់បង់ជីវិត ឬជាកិច្ចសន្យាដែលធ្វើឱ្យក្រុមហ៊ុនធានារ៉ាប់រងបង់ប្រាក់សំណងទៅឱ្យក្រុមគ្រួសាររបស់អ្នកស្លាប់ ក្រោមលក្ខខណ្ឌដែលបានកំណត់ក្នុងប័ណ្ណធានារ៉ាប់រង។ ធានារ៉ាប់រងសុខភាព (Health Insurance) សម្រាប់ធានាឡើងវិញវេជ្ជសាស្ត្រការព្យាបាលជំងឺនិងដំណើរព្យាបាលផ្សេងៗវាជាប្រភេទធានាទូទៅមួយដែលកំពុងមានការចំណាយខ្ពស់ (ប្រមាណ២២.៦%នៃប្រាក់ធានាទូទៅ)។ ធានារ៉ាប់រងយានយន្ត (Motor Insurance) គឺជាការធានារ៉ាប់រងដែលគ្របដណ្តប់លើការខូចខាត ឬការខូចនានាដែលកើតឡើងចំពោះយានយន្តរបស់អ្នកដូចជាម៉ូតូឡាន ករណីមានគ្រោះថ្នាក់ឬចោរលួចអាចហៅម៉្យាងបានទៀតថាជាកិច្ចសន្យារវាងម្ចាស់យានយន្ត និងក្រុមហ៊ុនធានារ៉ាប់រងដែលធានាថា ប្រសិនបើកើតមានគ្រោះថ្នាក់ឬការខូចខាតលើយានយន្ត(ឬទៅលើអ្នកដទៃ) ក្រុមហ៊ុននឹងបង់ប្រាក់សំណងឱ្យសមរម្យតាមលក្ខខណ្ឌ (ប្រមាណ១៦.៣% នៃប្រាក់ធានាទូទៅ)។ ធានារ៉ាប់រងអចលនទ្រព្យ (Property Insurance) ជាកិច្ចសន្យារវាងម្ចាស់អចលនទ្រព្យនិងក្រុមហ៊ុនធានារ៉ាប់រងដែលផ្តល់ការជំនួយផ្នែកហិរញ្ញវត្ថុនៅពេលដែលអចលនទ្រព្យរបស់អ្នករងគ្រោះថ្នាក់ឬខូចខាតដូចជា អគ្គីភ័យ ទឹកជំនន់ បាក់ដីជាដើមមាន (៣៤.៨%)។ ធានារ៉ាប់រងមីក្រូ(Microinsurance) ឬធានារ៉ាប់រងខ្នាតតូចគឺជាធានារ៉ាប់រងដែលគ្របដណ្តប់លើហានិភ័យផ្សេងៗដូចជា សុខភាព ជីវិត គ្រោះថ្នាក់ដែលមានថ្លៃប្រាក់ធានារង(Premium)ទាបនិងផ្តោត

លើការចូលដល់បានសម្រាប់មនុស្សដែលមិនធ្លាប់មានធានារ៉ាប់រង យោងទៅតាមទិន្នន័យថ្មីបង្ហាញថាវិស័យធានារ៉ាប់រងកម្ពុជា កំពុងមានកំណើនជាមធ្យមនៅត្រីមាសទី១ ឆ្នាំ២០២៥ បុព្វលាភសរុបកើនដល់ប្រមាណ US$102.3 លានកើន6%ទៅពីត្រីមាសដូចគ្នា២០២៤ សម្រាប់ចន្លោះឆ្នាំ២០២៤ បុព្វលាភសរុបជា US$356.4 លានកើន 3.5% ធៀបទៅឆ្នាំ២០២៣ ការចេញបង់សំណង (claims) ក៏ខ្ពស់ដល់ប្រមាណ US$ 79.7 លានក្នុងឆ្នាំ២០២៤ (កើន១៨.៩%) ទោះវាស្ថិតនៅលើការលូតលាស់តែវិស័យធានារ៉ាប់រងកម្ពុជាជួបការពិបាកជាច្រើនទិន្នន័យបង្ហាញថា កម្រិតគ្របដណ្តប់ធានារនៅតែទាបចំណែក GDP~1.16% លោកប៊ូច័ន្ទភីរូ អគ្គនាយក IRC បានអំពាវនាវថា ត្រូវការការបង្កើនយុទ្ធនាការផ្សព្វផ្សាយសិក្សា និងព័ត៌មានដល់សាធារណៈអំពីអត្ថប្រយោជន៍នៃធានារ៉ាប់រង ផ្នែកសេវាកម្មគណនេយ្យ ក៏ត្រូវបានលើកទឹកចិត្តឱ្យមានការរៀបចំ ឬធ្វើសិក្ខាសាលាដើម្បីឆ្លើយតបនឹងIFRS17 សមរម្យក្នុងវិស័យផងដែរការកើនឡើងនៃការចេញបង់សំណង និងសម្រួលឱ្យមានការផ្លាស់ប្តូរនូវទំហំធនធាន។

## ៣.២ គោលការណ៍នៃការរីកចម្រើននៃវិស័យហិរញ្ញវត្ថុនៅកម្ពុជា

### ៣.២.១ ការធានាស្ថិរភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ការធានាស្ថិរភាពសេដ្ឋកិច្ច គឺជាគោលការណ៍ដ៏សំខាន់មួយរបស់រាជរដ្ឋាភិបាលកម្ពុជាដើម្បីធ្វើឱ្យសេដ្ឋកិច្ចរីកចម្រើននិងបន្តក្នុងរយៈពេលវែងនៅឆ្នាំ២០២៤ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័ត Medium Term Fiscal Framework (MTFF) 2024–2027 ដើម្បីប្រាកដថាការចំណាយសាធារណៈត្រូវស្ថិតក្រោមការត្រួតពិនិត្យយ៉ាងច្បាស់ MTFF កំណត់អត្រាកង្វះធនធានសាធារណៈនៅប្រហែល ៣.០% នៃ GDP ក្នុងឆ្នាំ២០២៤ ហើយនឹងបន្ថយចុះសល់ ២.៤% នៃ GDP នៅឆ្នាំ២០២៥ ដើម្បីចៀសវាងលើបញ្ហាបំណុលជំនួសមកវិញបណ្តាញ Single Portal របស់ MEF និងគម្រោង Informal Economy Strategy 2023–2028 ជួយពង្រឹងប្រសិទ្ធភាពក្នុងការប្រមូលពន្ធ។ ការគាំទ្រវិស័យឯកជនជាម៉ូទ័រសំខាន់នៃកំណើនសេដ្ឋកិច្ចយោងតាមច្បាប់ (Law on Investment 2021) ដែលអនុវត្តជាផ្លូវការចាប់ពីឆ្នាំ២០២៣-២០២៤ បង្កើនការវិនិយោគបរទេសបង្កើនភាពងាយស្រួលក្នុងការធ្វើអាជីវកម្មនិងចុះបញ្ជីក្រុមហ៊ុនតាមប្រព័ន្ធអេឡិចត្រូនិក។ ចំពោះការរក្សាអត្រាអតិបរិមា (inflation) និងគ្រប់គ្រងការផ្គត់ផ្គង់លុយត្រូវបានធនាគារជាតិ (NBC) ចេញអនុវត្តន៍គោលដៅអត្រាអតិបរិមានៅក្រោម ៥% ជាមធ្យមដើម្បីរក្សាស្ថិរភាពថ្លៃលក់និងការទិញដូរ លើសពីនេះ NBC ក៏បានថែរក្សា Reserve Requirement Ratios ដើម្បីគ្រប់គ្រងលុយនៅក្នុងប្រព័ន្ធធនាគារ និងការប្រមូលសមតុល្យភាពការទិញដូរអន្តរជាតិកាន់តែមានប្រសិទ្ធភាព។ សម្រាប់វិធានការ macroprudential សម្រាប់ការត្រួតពិនិត្យហានិភ័យ និងការបង្កើនស្ថិរភាពប្រព័ន្ធហិរញ្ញវត្ថុដើម្បីពង្រឹងធនាគារ ឬស្ថាប័នឥណទានក៏ដូចជាការសិក្សានិងរៀបចំ Deposit Insurance Scheme ការពារឥណទានដល់អ្នកដាក់ទុន និងត្រួតពិនិត្យហានិភ័យប្រព័ន្ធហិរញ្ញវត្ថុជាសរុប។ ការគ្រប់គ្រងនយោបាយហិរញ្ញវត្ថុ (Monetary Policy) ដោយធនាគារជាតិនៃកម្ពុជាមានអំណាចក្នុងការកំណត់អត្រាការប្រាក់ស្តង់ដារ (policy interest rates) ដើម្បីឆ្ពោះទៅរកគោលដៅមានតុល្យភាពកំណើនសេដ្ឋកិច្ចដើម្បីទប់ស្កាត់អត្រាអតិផរណា (inflation) ធនាគារជាតិនៃកម្ពុជាគ្រោងពិនិត្យនិងចេញផ្សាយអត្រា (base rate) ឱ្យសមរម្យជាមួយស្ថានភាពថវិកា និងការគ្រប់គ្រងចរន្តប្រាក់ក្នុងប្រព័ន្ធ។ ធនាគារជាតិនៃកម្ពុជា (NBC) ស្ថាប័នប្រកាសលើ open market operations ដូចជាការទិញនិងលក់អចលនទ្រព្យរដ្ឋបាល (government securities) ដើម្បីត្រួតពិនិត្យអត្រាគុណភាពប្រាក់អាចប្រើបាន (liquidity) នៅ

ក្នុងប្រព័ន្ធធនាគារ ដូច្នេះប្រសិនបើធនាគារជាតិនៃកម្ពុជា(NBC) ចង់បន្ថយបរិមាណប្រាក់នៅលើទីផ្សារនឹងលក់មូលបត្រដើម្បីទាយយកដុល្លារពីស្ថាប័នធនាគារ ឬស្ថាប័នហិរញ្ញវត្ថុផ្សេងទៀត។ គ្រប់គ្រងប្រព័ន្ធធនាគារ និងស្ថាប័នឥណទានមានគោលបំណងសំខាន់ ដើម្បីធានាថាធនាគារនិងស្ថាប័នឥណទាន microfinance institutions, credit firms មានប្រតិបត្តិការដោយប្រុងប្រយ័ត្នមានប្រព័ន្ធត្រួតពិនិត្យខ្ពស់ត្រូវពិនិត្យថាមានបរិមាណទឹកប្រាក់គ្រប់គ្រាន់ adequate capital និងមានគុណភាពល្អ asset quality ដើម្បីជៀសវាងហានិភ័យ (credit risk, liquidity risk) និងហានិភ័យផ្សេងៗ។

**៣.២.២ ការអភិវឌ្ឍវិស័យធនាគារ និងស្ថាប័នឥណទាន**

ដើម្បីអភិវឌ្ឍសមត្ថភាពវិស័យធនាគារនិងស្ថាប័នឥណទានរាជរដ្ឋាភិបាលកម្ពុជានិងធនាគារជាតិបានបង្កើនសេវាកម្មឱ្យ SMEs អ្នកប្រើប្រាស់និងអង្គភាពឯកជនអាចចូលដំណើរការលឿនប្រកបដោយប្រសិទ្ធភាពហើយតម្លៃសមរម្យ ពង្រឹងសមត្ថភាពធនាគារ និងស្ថាប័នឥណទានកំណត់អត្រាទុនអប្បបរមា (Minimum Capital Requirements) NBCបានបន្តអនុវត្តលក្ខខណ្ឌទុនអប្បបរមាដែលបានកំណត់ឡើងថ្មីសម្រាប់ធនាគារនិង MFI ដើម្បីធានាបាននូវស្ថិរភាពស្ថាប័ននិងសមត្ថភាពសងប្រាក់ក្នុងករណីខាតបង់វាយតម្លៃសមត្ថភាពប្រតិបត្តិការ (On-site & off-site supervision) NBC បានពង្រឹងប្រព័ន្ធត្រួតពិនិត្យមើលប្រតិបត្តិការទាំងផ្ទាល់និងឆ្ងាយ ដើម្បីពិនិត្យសុខភាពស្ថាប័នហិរញ្ញវត្ថុនិងធានាបាននូវការប្រើប្រាស់ទុនមានប្រសិទ្ធភាព។ ការជំរុញឱ្យSMEsប្រើប្រាស់ប្រាក់កម្ចី NBC និងរដ្ឋាភិបាលបានសហការជាមួយស្ថាប័នអភិវឌ្ឍអន្តរជាតិដូចជាADB,IFCនិងបានចូលរួមចុះកិច្ចព្រមព្រៀងជាមួយស្ថាប័នធានាឥណទានCredit Guarantee Scheme (CGCC) ដើម្បីផ្តល់អនុសាសន៍ការគាំទ្រឥណទានដល់អាជីវកម្មតូចៗនិង មធ្យម ស្ត្រី អ្នកជំនួញទាំងក្នុងស្រុកនិងក្រុង។ កិច្ចសហការនេះ អនុញ្ញាតឱ្យធនាគារ និងមីក្រូហិរញ្ញវត្ថុអាចផ្តល់ឥណទានជូនទៅអាជីវកម្មនានាបានច្រើនស្ថាប័នធនាគារ និងMFIត្រូវបានលើកទឹកចិត្តឱ្យអភិវឌ្ឍ “digital loan processing platforms” ដើម្បីឱ្យការដាក់ពាក្យខ្ចីប្រាក់អាចធ្វើបានតាមអ៊ីនធឺណិត ឬតាមទូរស័ព្ទជួយកាត់បន្ថយពេលវេលា និងថ្លៃដើមប្រតិបត្តិការ បង្កើនការប្រកួតប្រជែងនិងការចូលរួមក្នុងទីផ្សារ NBC បានអនុញ្ញាតឱ្យធនាគារថ្មីៗ ដូចជា Chip Mong Bank និង Orient Bank ជាឧទាហរណ៍ដើម្បីបង្កើតការប្រកួតប្រជែង និងបង្កើនជម្រើសសេវាហិរញ្ញវត្ថុ NBC កំពុងអភិវឌ្ឍ “Open Banking Framework” ដើម្បីឱ្យធនាគាររួមបញ្ចូលបច្ចេកវិទ្យា និងការផ្តល់សេវាជាមួយ FinTechs ផ្សេងៗ ដូចជា e-wallets និងពាណិជ្ជកម្មអេឡិចត្រូនិកដើម្បីផ្តល់ជម្រើសសេវាផ្សេងទៀតដល់អតិថិជន។ NBC កំពុងលើកកម្ពស់ការចុះបន្ថែមសេវាធនាគារទៅតំបន់ជនបទតាមរយៈ Banking Agents ដូចជាអ្នកលក់ផលិតផលរដ្ឋបាលឬអ្នកជួញដូរត្រូវបានណែនាំឱ្យធ្វើសេវាជំនួសដោយសុវត្ថិភាព ស្ថាប័នឥណទានត្រូវបានលើកទឹកចិត្តឱ្យបង្កើតកម្មវិធីអប់រំហិរញ្ញវត្ថុប្រជាពលរដ្ឋដើម្បីអភិវឌ្ឍគំនិតរបស់ពួកគេក្នុងការប្រើប្រាស់សេវាឥណទាន និងបញ្ចូនប្រាក់យ៉ាងមានទំនួលខុសត្រូវ។ វិធានការទាំងនេះបានបង្ហាញថា ការអភិវឌ្ឍវិស័យធនាគារ និងស្ថាប័នឥណទាននៅកម្ពុជាកំពុងផ្លាស់ប្តូរពីស្ថានភាពប្រពៃណីទៅជាប្រព័ន្ធឌីជីថលប្រកបដោយការប្រកួតប្រជែងខណៈពេលដែលSMEs និងប្រជាពលរដ្ឋកាន់តែអាចចូលដំណើរការប្រាក់កម្ចីដោយងាយស្រួលសុវត្ថិភាពនិងថ្លៃសមរម្យ។

**៣.២.៣ ការលើកកម្ពស់សេវាហិរញ្ញវត្ថុឌីជីថល**

ក្រោមគោលការណ៍ការលើកកម្ពស់សេវាហិរញ្ញវត្ថុឌីជីថល(Promotion of Digital Financial Services) រដ្ឋាភិបាលកម្ពុជានិងធនាគារជាតិបានអនុវត្តន៍យុទ្ធសាស្ត្រនានាជំរុញឱ្យប្រព័ន្ធហិរញ្ញវត្ថុឌីជីថលក្លាយជាឧបករណ៍សំខាន់សម្រាប់ ការបង់ប្រាក់ ទូទាត់ប្រាក់ និងចូលដំណើរការសេវាឥណទានបែបឌីជីថលស្របទៅនឹង FinTech Development Policy 2023–2028គោលនយោបាយនេះផ្តោតលើគោលដៅសំខាន់ៗដូចជាបង្កើតបរិបទផ្លូវច្បាប់ និងនយោបាយជាមូលដ្ឋាន ខណៈធនាគារជាតិកំពុងអភិវឌ្ឍច្បាប់គ្រប់គ្រង FinTech និងបង្កើត regulatory sandbox ដើម្បីអនុញ្ញាតឱ្យសេវាឌីជីថលថ្មីៗត្រូវបានសាកល្បងក្នុងបរិបទមានការត្រួតពិនិត្យជំរុញភាពច្នៃប្រឌិត និងការចូលរួមរបស់FinTechsធនាគារជាតិបានធ្វើកិច្ចសហប្រតិបត្តិការជាមួយសហគមន៍ FinTech និងបង្កើត Cambodia FinTech Association (CFA) ដើម្បីប្រើប្រាស់ ecosystem កសាងទំនុកចិត្តនិងការពារអ្នកប្រើប្រាស់ ដំណើរការបង្កើត Consumer Protection Framework សម្រាប់សេវាឌីជីថលនិងកំណត់ស្តង់ដារសុវត្ថិភាពទិន្នន័យ (data privacy & cybersecurity)។លើសពីនេះមានការបង្កើនជំនាញឌីជីថល និងការសិក្សាហិរញ្ញវត្ថុចូលរួមបណ្តុះបណ្តាលប្រជាពលរដ្ឋឱ្យប្រើប្រាស់សេវាឌីជីថលដោយយល់ដឹងនិងមានទំនួលខុសត្រូវ ចូលរួមលើកកម្ពស់ដំណើរការបង់ប្រាក់ឌីជីថលគ្រប់ទម្រង់ដោយសហការជាមួយបណ្តាញគ្រប់គ្រងទូទាត់ក្នុងការសម្របសម្រួល interoperability រវាង e-wallets និងធនាគារ។យ៉ាងណាវិញចំពោះប្រព័ន្ធបង់ប្រាក់ឌីជីថលនិងប្លុកឈេនមានការអភិវឌ្ឍ Bakong System ប្រព័ន្ធបង់ប្រាក់ជាសកលរបស់ NBC (Bakong) បានផ្តល់សេវាបង់ប្រាក់ឆាប់រហ័ស real-time ទៅស្ថាប័នហិរញ្ញវត្ថុគ្រប់ប្រភេទដោយបំពាក់នូវបច្ចេកវិទ្យា blockchain–based distributed ledger ដែលធានាសុវត្ថិភាពនិងប្រតិបត្តិការត្រឹមត្រូវប្រជាពលរដ្ឋអាចប្រើប្រាស់ Bakong System តាមស្មាតហ្វូនSmartphone ដើម្បីផ្ទេរប្រាក់ដោយមិនចាំបាច់មានគណនីធនាគាររួមបញ្ចូលទាំង e-wallets និង QR Code Standard (KHQR)។ NBC បានបង្កើត KHQR គ្រប់គ្រងជាស្តង់ដារបង់ប្រាក់តាម QR រវាងសេវាកម្ម e-wallets ជាឧទាហរណ៍ផ្សារទំនើប ក្រុមហ៊ុន SMEs និងអាជីវករតូចធំចាប់ផ្តើមទទួលបង់ប្រាក់តាម KHQR កាន់តែច្រើនបូករួមទាំងការផលិតនិងលើកកម្ពស់សេវាថ្មីៗមួយចំនួនទាក់ទងនឹង FinTechs (ឧ. TrueMoney, Wing, Pi Pay) ក៏បាននាំមកនូវសេវាថ្មីៗដូចជា Micro-loans via apps, Bill payments, tax payments, and e-commerce checkouts , Cross-border payments ជាមួយប្រទេសជិតខាង ( ឧ. ឡាវ វៀតណាម) តាមប្រព័ន្ធ Bakong–Lao QR Interlinking។ ហេតុនេះទើបមានការកើនឡើងនៃការប្រើប្រាស់សេវាឌីជីថលយោងតាមរបាយការណ៍ចាប់ពីឆ្នាំ២០២២ដល់ឆ្នាំ២០២៤ ការប្រើប្រាស់ mobile banking និង e-wallets កើនដល់ជាង១៤លានគណនីនៅក្នុងប្រទេស (ប្រហែល ៨០% នៃប្រជាជនពេញវ័យ) អត្រាការបង់ប្រាក់តាមសេវាឌីជីថលកើនឡើងជិត 50% នៃប្រតិបត្តិការទូទាត់ក្នុងប្រព័ន្ធបង្ហាញពីភាពទាក់ទាញខ្ពស់។ការលើកកម្ពស់សេវាហិរញ្ញវត្ថុឌីជីថលជួយឱ្យប្រជាពលរដ្ឋក្រុមហ៊ុន SMEs និងស្ថាប័នផ្ទាល់ខ្លួនអាចចូលប្រើប្រាស់សេវាហិរញ្ញវត្ថុបានយ៉ាងងាយស្រួលមានសុវត្ថិភាពសមស្របតាមសម័យឌីជីថល វាក៏ជាជំហានសំខាន់ក្នុងការជំរុញ financial inclusion និងសេដ្ឋកិច្ចឌីជីថលជាសកល។

### ៣.២.៤ ការជំរុញទីផ្សារហិរញ្ញវត្ថុក្នុងស្រុក និង Financial Inclusion

គោលនយោបាយរបស់រាជរដ្ឋាភិបាលសម្រាប់ទីផ្សារហិរញ្ញវត្ថុក្នុងស្រុកមាន ការលើកទឹកចិត្តឱ្យអភិវឌ្ឍកម្រិតទីផ្សារមូលធន(ដូចជាទីផ្សារហ៊ុននិងទីផ្សារប័ណ្ណរដ្ឋ)ដើម្បីប្រមូលទុនក្នុងស្រុក ការចូលរួម

ហិរញ្ញវត្ថុរដ្ឋអនុវត្តន៍យុទ្ធសាស្ត្រជាតិ National Financial Inclusion Strategy (NFIS 2019–2025) NFIS គឺជាគម្រោងជាតិសំខាន់ដែលមានគោលដៅធ្វើឱ្យអត្រាប្រជាពលរដ្ឋពេញវ័យ (ages 15+) ដែលចូលប្រើប្រាស់សេវាហិរញ្ញវត្ថុកើនដល់70% ក្នុងឆ្នាំ២០២៥ ជំរុញឱ្យស្ត្រី និងប្រជាជននៅតាមតំបន់ជនបទចូលរួមប្រើប្រាស់សេវាហិរញ្ញវត្ថុបានយ៉ាងស្មើភាព។ បង្កើតមូលដ្ឋាន គោលនយោបាយគាំទ្រទៅលើសេវាហិរញ្ញវត្ថុឌីជីថល microfinance និងអភិវឌ្ឍ e-KYC ចំណេះដឹងផ្នែកហិរញ្ញវត្ថុ (Financial Literacy) NBC បានធ្វើសកម្មភាពផ្សព្វផ្សាយសាធារណៈនៅតាមសាលារៀន ទូរទស្សន៍ Facebook Page និងកម្មវិធីផ្សេងៗដើម្បីបង្ហាញពីរបៀបប្រើប្រាស់ e-wallets និងធនាគារ ការប្រុងប្រយ័ត្នលើការលួច identity theft អ្វីទៅជាប្រាក់កម្ចីមានទំនួលខុសត្រូវ NBC បង្កើតកម្មវិធី “Let’s Talk Money” ជាកម្មវិធីតាមប្រព័ន្ធផ្សព្វផ្សាយអប់រំពីការគ្រប់គ្រងប្រាក់ និងហានិភ័យផ្ទាល់ខ្លួន។ ធនាគារ និង MFI ត្រូវបានជំរុញឱ្យបើកសាខាហើយផ្តល់សេវា branchless banking តាមរយៈ Banking Agents នៅតំបន់ជនបទស្ត្រីបានចូលរួមក្នុងសេវាឥណទាននិងសន្សំកាន់តែខ្ពស់ (ជាង ៥០% នៃអតិថិជន MFI ជាស្ត្រី) កម្មវិធី Digital ID & e-KYCរបៀបចុះឈ្មោះបែបឌីជីថលដើម្បីជួយឱ្យប្រជាពលរដ្ឋអាចបើកគណនីបានលឿនហើយមានប្រសិទ្ធភាព ធនាគារកណ្តាល NBC បង្កើត Consumer Protection Framework ដើម្បីការពារសិទ្ធិអ្នកប្រើប្រាស់ហើយបានបញ្ជាក់ថាអ្នកផ្តល់សេវាហិរញ្ញវត្ថុត្រូវបង្ហាញលក្ខខណ្ឌការខ្ចីប្រាក់ឬការបង់ប្រាក់ឱ្យច្បាស់បង្កើតលក្ខខណ្ឌសុវត្ថិភាពសម្រាប់ e-wallet និង Mobile Banking ដូចជា OTP, PIN និង biometric authentication NBC ក៏បានដាក់អនុវត្តបម្រើសេវាជូនប្រជាពលរដ្ឋនៅតាមសាខានិងអនឡាញដើម្បីឱ្យអតិថិជនអាចបណ្តឹងឬស្នើសុំជំនួយពេលមានបញ្ហា។ ជំរុញ Microfinance និងហិរញ្ញវត្ថុគ្រប់ជ្រុងជ្រោយដោយបង្កើត “Credit Guarantee Schemes” ជាសាធារណៈ/ឯកជន ដើម្បីជួយសហគ្រាសតូចអាចយកប្រាក់ខ្ចីបានដោយមានការធានាគាំទ្រស្ថាប័នឥណទានធំៗបំពេញបេសកកម្មសង្គមដោយកាត់បន្ថយអត្រាការប្រាក់និងលើកកម្ពស់សេវាសន្សំសម្រាប់គ្រួសារក្រីក្រ រីឯគោលនយោបាយ Financial Inclusion ជារបៀបសំខាន់មួយសម្រាប់ជំរុញសេដ្ឋកិច្ច (grassroots economy) ដោយធានាថាប្រជាពលរដ្ឋគ្រប់រូបអាចចូលរួមក្នុងប្រព័ន្ធហិរញ្ញវត្ថុបង្កើតឱ្យកើនសមត្ថភាពគ្រប់គ្រងប្រាក់និងរួមចំណែកសំខាន់ក្នុងការអភិវឌ្ឍប្រទេស។

### ៣.២.៥ ការចូលរួមអន្តរជាតិ និងការជំរុញវិនិយោគ

ការចូលរួមជាមួយសហគមន៍អន្តរជាតិ គឺជាផ្នែកមួយដ៏សំខាន់នៃគោលនយោបាយសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងគោលបំណងជំរុញវិស័យហិរញ្ញវត្ថុ និងបង្កើនស្ថិរភាពសេដ្ឋកិច្ចរបស់ប្រទេស។ នៅក្នុងឆ្នាំ២០២៤ កម្ពុជាបានបន្តសហការយ៉ាងជិតស្និទ្ធជាមួយស្ថាប័នអន្តរជាតិធំៗនិងបានអនុវត្តន៍គោលនយោបាយដែលសមស្របនឹងទិសដៅអភិវឌ្ឍន៍អាស៊ី បង្កើនកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នអន្តរជាតិធំៗមានធនាគារ World Bank – WB រាជរដ្ឋាភិបាលកម្ពុជាបានបន្តសហការជាមួយ WB ដើម្បីអនុវត្តគម្រោង Loan for SMEs and Green Economy និងគម្រោងគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈពង្រឹងសមត្ថភាពសេវាធនាគារសាធារណៈ។ កម្ពុជាបានសហការជាមួយ International Monetary Fund - IMF ក្នុងការត្រួតពិនិត្យស្ថានភាពសេដ្ឋកិច្ច តាមរយៈការអនុវត្តន៍ Article IV Consultation និងទទួលបានអនុសាសន៍អំពីការគ្រប់គ្រងបំណុល ការបង្កើនប្រសិទ្ធភាពសេវាធនាគារ ការផ្លាស់ប្តូរប្រាក់ និងនយោបាយលុយ IMF បានណែនាំឱ្យ NBC បញ្ឈប់វិធានការអន្តរវិនិយោគ (loan forbearance) ដើម្បីធ្វើឱ្យប្រព័ន្ធធនាគារមានស្ថិរភាព

ជាងមុន ចូលរួមធ្វើវិភាគហានិភ័យនិងអភិវឌ្ឍសម្រាប់ការទប់ស្កាត់វិបត្តិហិរញ្ញវត្ថុក្នុងតំបន់ ASEAN+3 Macroeconomic Research Office (AMRO)។មិនតែប៉ុណ្ណោះកម្ពុជានិងធនាគារអភិវឌ្ឍន៍អាស៊ាន (Asian Development Bank - ADB)បានចុះកិច្ចសហការជាមួយគម្រោង Capacity Building for Financial Sector Development ដែលផ្តោតលើការអភិវឌ្ឍសេវាហិរញ្ញវត្ថុឌីជីថល ការបណ្តុះបណ្តាលបុគ្គលិកស្ថាប័នហិរញ្ញវត្ថុ ការគ្រប់គ្រងហានិភ័យ និងស្តង់ដារសាជីវកម្មជាតិសម្រាប់MFI/បណ្តាញធនាគារ។ គោលនយោបាយសមស្របតាមគោលដៅអភិវឌ្ឍន៍ធនធាននិងបច្ចេកវិទ្យាថ្មីរួមចំណែកក្នុង SDGs (Sustainable Development Goals)របស់អង្គការសហប្រជាជាតិដោយកែសម្រួលគោលនយោបាយហិរញ្ញវត្ថុឱ្យគាំទ្របច្ចេកវិទ្យាថ្មី កម្ពុជាបានជម្រុញគោលនយោបាយបៃតងនិងឌីជីថលដូចជា ផែនការអភិវឌ្ឍ FinTech 2023–2028 ការផ្តល់កម្ចីបៃតង (Green Loans) ដោយសហការជាមួយ IFC និង UNDP បង្កើត Green Bond Guidelines ចូលរួមក្នុងចក្ខុវិស័យ ASEAN Digital Economy Framework Agreement (DEFA) ដើម្បីសម្រួលពាណិជ្ជកម្មឌីជីថល និងអភិវឌ្ឍបច្ចេកវិទ្យា blockchain, AI, និង open banking។ ការចូលរួមសកម្មភាពជាមួយសហគមន៍អន្តរជាតិ និងការដាក់ចេញគោលនយោបាយទាក់ទាញវិនិយោគបរទេសកំពុងរួមចំណែកយ៉ាងសំខាន់ក្នុងសេដ្ឋកិច្ចទាន់សម័យមានតម្លាភាព និងទាក់ទាញបាននូវវិនិយោគក្រៅប្រទេសប្រកបដោយគុណភាពជាថ្នាក់ដ៏សំខាន់ក្នុងគម្រោងរយៈវែងរបស់កម្ពុជាដើម្បីឆ្ពោះទៅជាប្រទេសមានចំណូលខ្ពស់ក្នុង១-២ឆ្នាំ។

## ៣.៣ ការរីកចម្រើននៃវិស័យហិរញ្ញវត្ថុចំពោះសេដ្ឋកិច្ចនៅកម្ពុជា

ការរីកចម្រើននៃវិស័យហិរញ្ញវត្ថុពិតជាមានសារៈសំខាន់យ៉ាងខ្លាំង ព្រមទាំងជាកត្តាដែលជះឥទ្ធិពលដល់សេដ្ឋកិច្ចកម្ពុជាដោយសារតែវាជាស្នូលសំខាន់ក្នុងការអភិវឌ្ឍក៏ដូចជាការលើកកម្ពស់សេដ្ឋកិច្ច ការពង្រីកឧស្សាហកម្ម ការកែលម្អជីវភាពរស់នៅ និងការផ្តល់ជូននូវសេវាកម្មដែលមានប្រសិទ្ធភាពសម្រាប់ប្រជាជនខាងក្រោមគឺជាសារៈសំខាន់នៃការរីកចម្រើនវិស័យហិរញ្ញវត្ថុចំពោះសេដ្ឋកិច្ចកម្ពុជា៖

1. បង្កើតការងារនិងកាត់បន្ថយភាពក្រីក្រ : វិស័យមីក្រូហិរញ្ញវត្ថុ (Microfinance) និងធនាគារកសិកម្មជួយបើកឱកាសឱ្យប្រជាជនតាមជនបទ និងប្រជាជនដែលមានចំណូលទាបអាចចាប់ផ្តើមអាជីវកម្មតូចៗ និងអាជីវកម្មផ្ទាល់ខ្លួនដំណើរការប្រើប្រាស់សេវាឥណទាននិងសេវាហិរញ្ញវត្ថុផ្សេងៗបានជួយឱ្យគ្រួសារកំពុងមានប្រាក់ចំណូលទាបអាចបង្កើនទ្រព្យ ចំណាយលើការថែទាំសុខភាព អភិវឌ្ឍន៍បេបរស់នៅព្រមទាំងបង្កើតការងារបង្កើនផលិតភាពនិងចូលរួមកាត់បន្ថយអត្រាចំណាក់ស្រុក។
2. ជម្រុញការវិនិយោគនិងអាជីវកម្ម : ចូលរួមជាមួយធនាគារនិងស្ថាប័នហិរញ្ញវត្ថុផ្សេងៗជួយធ្វើឱ្យអាជីវកម្មឯកជនអាចពង្រឹងដំណើរការផលិត និងបង្កើនសមត្ថភាពប្រកួតប្រជែងវិស័យហិរញ្ញវត្ថុមានសារៈសំខាន់ក្នុងការផ្តល់ប្រភពធនធានសម្រាប់អាជីវកម្មគ្រប់ទំហំទាំងទំហំតូចធំនិងមធ្យម ដោយផ្តល់ឥណទានសម្រាប់វិនិយោគនូវគម្រោងដែលមានសក្តានុពលដោយអមជាមួយប្រព័ន្ធហិរញ្ញវត្ថុដែលមានប្រសិទ្ធភាពអាចធ្វើការទាក់ទាញ ការវិនិយោគក្នុងស្រុកនិងក្រៅស្រុកបានកាន់តែងាយស្រួលប្រកបដោយទំនុកចិត្ត។
3. គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនិងបង្កើនចំណូលជូនរដ្ឋ : វិស័យហិរញ្ញវត្ថុគាំទ្រ ដល់សមត្ថភាពរបស់រដ្ឋក្នុងការបង្កើនចំណូលបូករួមទាំងគ្រប់គ្រងការចំណាយសាធារណៈ ប្រព័ន្ធពន្ធ

ជាវដែលមានប្រសិទ្ធភាព និងស្ថាប័នហិរញ្ញវត្ថុធ្វើឱ្យរដ្ឋអាចប្រមូលពន្ធបានប្រសើរដោយរួមបញ្ចូលការទូទាត់ពន្ធតាមអេឡិចត្រូនិចនិងមានការតាមដានប្រាក់ចំណូលច្បាស់លាស់ ចូលរួមប្រើប្រាស់សេវាធនាគារដោយសាធារណជនបន្ថែម និងឆ្លើយតបលើការចំណាយថវិការដ្ឋដូចជាការទូទាត់ប្រាក់ខែរបស់មន្ត្រីរដ្ឋឬគម្រោងសាធារណៈ វាជួយរដ្ឋក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឱ្យមានសមភាពប្រកបដោយទំនួលខុសត្រូវ និងភាពមានប្រសិទ្ធភាពក្នុងការប្រើប្រាស់ធនធាន។

4. ការកែលម្អប្រព័ន្ធហិរញ្ញវត្ថុ និងការផ្លាស់ប្តូរបច្ចេកវិទ្យា : ការរីកចម្រើននៃវិស័យហិរញ្ញវត្ថុជាផ្នែកមួយនៃការអភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុដោយប្រព័ន្ធនេះអាចជួយពង្រីកការផ្តល់សេវាកម្មដល់ប្រជាជននិងអាជីវកម្មធ្វើឱ្យប្រព័ន្ធឌីជីថល (digital finance) មានការពង្រីកនិងប្រសិទ្ធភាពខ្ពស់បន្តអភិវឌ្ឍប្រព័ន្ធឌីជីថល និងការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗដូចជា mobile banking និង digital payments ជួយបង្កើនប្រសិទ្ធភាពនៃការទូទាត់ និងប្រើប្រាស់បច្ចេកវិទ្យាថ្មី។ បង្កើនការចូលរួមរបស់ប្រជាជន ដោយឱ្យប្រជាជនបានអាចចូលរួមក្នុងប្រព័ន្ធហិរញ្ញវត្ថុថ្មីៗជាមួយនឹងសេវាកម្មដូចជា mobile banking, online banking និងការប្រាក់ឌីជីថល។
5. លើកកម្ពស់បច្ចេកវិទ្យា និងសេដ្ឋកិច្ចឌីជីថល : វិស័យហិរញ្ញវត្ថុមានតួនាទីសកម្មក្នុងការលើកកម្ពស់បច្ចេកវិទ្យានិងជំរុញសេដ្ឋកិច្ចឌីជីថល ការរីកចម្រើននៃបច្ចេកវិទ្យាដូចជា Mobile Banking, E-Wallet, QR Code Payment និងបណ្តាញបង់ប្រាក់អេឡិចត្រូនិចបានផ្តល់ភាពងាយស្រួលល្បឿនសុវត្ថិភាពនិងជំរុញសេដ្ឋកិច្ចឱ្យមានសកម្មភាពខ្លាំង ការចូលរួមនេះក៏ជួយឱ្យប្រជាជនមានចំណូលទាប និងនៅជនបទអាចប្រើសេវាហិរញ្ញវត្ថុបានងាយស្រួលជាងមុន ហើយជួយកាត់បន្ថយភាពរើសអើងផ្នែកហិរញ្ញវត្ថុនិងបង្កើតឱកាសស្មើភាពសម្រាប់គ្រប់គ្នា។
6. ការផ្គត់ផ្គង់ហិរញ្ញវត្ថុសម្រាប់ការវិនិយោគ : មានតួនាទីសំខាន់ក្នុងការជំរុញការអភិវឌ្ឍន៍អាជីវកម្មនិងវិស័យឧស្សាហកម្មនៅកម្ពុជា ផ្តល់ឱ្យក្រុមហ៊ុនឬអាជីវកម្មអាចទទួលបានឧបករណ៍ហិរញ្ញវត្ថុដូចជាឥណទាន មូលនិធិវិនិយោគ ប្រាក់បង់ដើម និងប្រាក់ប្រើប្រាស់បឋមសម្រាប់ការចាប់ផ្តើមឬពង្រីកអាជីវកម្ម ផ្គត់ផ្គង់ហិរញ្ញវត្ថុគ្រប់គ្រាន់ ទាន់ពេលវេលាជួយស្តារនិងជំរុញសេដ្ឋកិច្ចឱ្យមានការអភិវឌ្ឍប្រកបដោយចីរភាព។
7. ជំរុញកំណើនសេដ្ឋកិច្ចជាតិ : វិស័យហិរញ្ញវត្ថុមានតួនាទីសំខាន់ក្នុងការជំរុញសេដ្ឋកិច្ចកម្ពុជាស្ថាប័នហិរញ្ញវត្ថុដូចជាធនាគារនិងក្រុមហ៊ុនឥណទានតូច-មធ្យមបានផ្តល់ឥណទានជាច្រើនសម្រាប់សហគ្រាសទំហំតូច (SMEs) ដែលជាចលករសំខាន់នៃសេដ្ឋកិច្ច។ វិស័យហិរញ្ញវត្ថុក៏បានទាក់ទាញវិនិយោគទាំងក្នុងស្រុក និងក្រៅស្រុកដោយមានទុនវិនិយោគចូលសរុបជាង 6.9ប៊ីល្យុនដុល្លារ។ បន្ថែមពីនេះការអភិវឌ្ឍន៍សេវាហិរញ្ញវត្ថុឌីជីថលដូចជា Mobile Banking, e-wallet និងប្រព័ន្ធ Bakong បានធ្វើឱ្យប្រជាជនមានការចូលរួមកាន់តែច្រើនក្នុងប្រព័ន្ធហិរញ្ញវត្ថុបន្ថែមលើការបញ្ចុះថ្លៃនិងពង្រឹងប្រសិទ្ធភាពប្រតិបត្តិការសេដ្ឋកិច្ចទូទៅ យោងតាមរបាយការណ៍របស់ ADB និង IMF អត្រាកំណើនសេដ្ឋកិច្ចមានការកើនឡើងនៃ GDP ប្រហែលជិត 6% ជាអនុភាពមួយដ៏សំខាន់សម្រាប់សេដ្ឋកិច្ចកម្ពុជា។

8. ស្ថិរភាពសេដ្ឋកិច្ច : ប្រព័ន្ធហិរញ្ញវត្ថុដែលមានប្រសិទ្ធភាពជួយធ្វើឱ្យសេដ្ឋកិច្ចមានស្ថិរភាព បង្កើនទំនុកចិត្តសម្រាប់អ្នកវិនិយោគ និងប្រជាជនការគ្រប់គ្រងប្រតិបត្តិការច្បាស់លាស់របស់ស្ថាប័នហិរញ្ញវត្ថុអនុញ្ញាតឱ្យប្រជាជនដំណើរការប្រតិបត្តិការយ៉ាងសុវត្ថិភាព ធនាគារជាតិនៃកម្ពុជា និងធនាគារជួញដូរបរទេសមានតួនាទីសំខាន់ ក្នុងការត្រួតពិនិត្យអត្រាប្តូរប្រាក់ផ្គត់ផ្គង់សាច់ប្រាក់ និងគ្រប់គ្រងអត្រាការប្រាក់ដើម្បីរក្សាស្ថិរភាពសេដ្ឋកិច្ច។ បន្ថែមពីនេះ ការគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋប្រកបដោយប្រសិទ្ធភាព និងទំនួលខុសត្រូវក៏ជួយឱ្យថវិការដ្ឋប្រើប្រាស់មានគោលដៅនិងទទួលបានផលប្រយោជន៍អតិបរមាផងដែរ។
9. ការលើកកម្ពស់សេដ្ឋកិច្ចក្នុងរយៈពេលវែង : ការរីកចម្រើននៃវិស័យហិរញ្ញវត្ថុអាចជួយជំរុញនិងកែលម្អសេដ្ឋកិច្ចក្នុងរយៈពេលវែង វិស័យនេះជួយពង្រីកការចំណាយនិងការវិនិយោគរបស់ប្រជាជនដែលសំខាន់សម្រាប់សេដ្ឋកិច្ច ការកើនឡើងនៃការវិនិយោគពីបរទេសនិងការអភិវឌ្ឍនៃវិស័យហិរញ្ញវត្ថុបានបង្ហាញពី ការពង្រីកនៃទីផ្សារវិនិយោគនាំឱ្យមានការប្រកួតប្រជែងល្អជាប្រយោជន៍សម្រាប់សេដ្ឋកិច្ចកម្ពុជា នៅពេលដែលប្រជាជនអាចទទួលបានសេវាហិរញ្ញវត្ថុល្អនិងមានសមត្ថភាពក្នុងការអនុវត្តន៍ការវិនិយោគ យើងអាចទស្សន៍ថាប្រជាជននឹងចំណេញពីការអភិវឌ្ឍន៍ប្រព័ន្ធនេះ។

# ជំពូកទី៤
# ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទខាងលើនេះរួចមក ក្រុមយើងខ្ញុំយល់ឃើញថា ការរីកចម្រើនវិស័យហិរញ្ញវត្ថុ នៅកម្ពុជាពិតជាមានសារៈសំខាន់យ៉ាងខ្លាំងចំពោះ ការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមជាតិ ហើយត្រូវបានដាក់គោលការណ៍ជាសមិទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាល ព្រមទាំង ជាដៃគូរអភិវឌ្ឍន៍ និងវិស័យឯកជនក្នុងការបង្កើនប្រព័ន្ធហិរញ្ញវត្ថុដែលមានប្រសិទ្ធភាពធន់នឹងវិបត្ត ថែមទាំង ឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។ ប៉ុន្តែទោះជាយ៉ាងណា ក៏ដោយការរីកចម្រើនវិស័យហិរញ្ញវត្ថុនេះ នៅតែមានចំណុចខ្លាំង និងចំណុចខ្សោយនៅជាមួយគ្នាជានិច្ច ហើយខាងក្រោមនេះជាការសង្ខេបអំពីការ វិភាគលើចំណុចខ្លាំង និងចំណុចខ្សោយដែលទាក់ទងនិងប្រធានបទ។

## ៤.១ ការវិភាគលើចំណុចខ្លាំង

- ស្ថិរភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុ : រដ្ឋាភិបាល និងធនាគារជាតិកម្ពុជាបានអនុវត្តគោលនយោបាយ ថវិកាប្រកបដោយទំនួលខុសត្រូវដើម្បីធានាស្ថិរភាពសេដ្ឋកិច្ច និងអត្រាអតិផរណា គោលនយោបាយ ថវិកាដែលផ្អែកលើ MTFF បានជួយបង្កើតសមតុល្យ និងភាពនិរន្តរភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ សាធារណៈ។
- ការលើកម្ពស់សេវាហិរញ្ញវត្ថុឌីជីថល : ការអភិវឌ្ឍន៍ប្រព័ន្ធ Bakong និងការអនុវត្ត KHQR ជម្រុញ ការទូទាត់ឌីជីថលក្នុងពេលជាក់ស្តែង(real-time)។ ការចូលរួមរបស់ប្រជាជនក៏មានកើនឡើងយ៉ាង ច្រើនដោយមានគណនី Mobile Banking និង e-wallets ជាង ១៤ លានគណនី (ប្រហែល ៨០% នៃមនុស្សពេញវ័យ)។
- ការលើកកម្ពស់ការច្បាប់ និងបទប្បញ្ញត្តិ : ការកែប្រែនិងពង្រឹងច្បាប់ទាក់ទងនឹងធនាគារ ក្រុមហ៊ុន ធានារ៉ាប់រងនិងវិស័យឥណទានថ្នាក់ក្រោមបានជួយបង្កើនទំនុកចិត្ត គណៈកម្មាធិការមានសមត្ថភាព ក្នុងការត្រួតពិនិត្យសកម្មភាពហិរញ្ញវត្ថុមានតួនាទីសំខាន់។
- ការរីកចម្រើននៃវិស័យធនាគារនិងស្ថាប័នឥណទាន : វិស័យធនាគារ និងស្ថាប័នឥណទានត្រូវបាន បង្កើនសមត្ថភាពតាមរយៈលក្ខខណ្ឌទុនអប្បបរមាថ្មី ការពង្រឹងការត្រួតពិនិត្យ និងការប្រើប្រាស់ វេទិកាឥណទាន។

សរុបជារួមមក ការរីកចម្រើននៃវិស័យហិរញ្ញវត្ថុកម្ពុជា មានការសម្របសម្រួលបានយ៉ាងល្អជាមួយ ការបម្រែបម្រួលសេដ្ឋកិច្ចជាតិនិងសកល ការចងសម្ព័ន្ធយុទ្ធសាស្ត្រជាតិ និងអន្តរជាតិក៏ជួយបង្កើនភាព ប្រកួតប្រជែងនិងការជឿជាក់លើប្រព័ន្ធហិរញ្ញវត្ថុប្រទេសកាន់តែខ្ពស់ក្នុងអនាគត។

## ៤.២ ការវិភាគលើចំណុចខ្សោយ

ទោះបីជាវិស័យហិរញ្ញវត្ថុកម្ពុជាមានចំណុចខ្លាំងជាច្រើន ដែលជាឧបករណ៍ជម្រុញសំខាន់សម្រាប់ការ អភិវឌ្ឍន៍សេដ្ឋកិច្ចដូចដែលបានរៀបរាប់ខាងលើក្តី ក៏នៅតែមានចំណុចខ្វះខាតមួយចំនួនដែលអាចក្លាយជា បញ្ហាប្រឈមដែលតម្រូវឱ្យមានការយកចិត្តទុកដាក់និងដំណោះស្រាយទាន់ពេល ចំណុចខ្វះខាតទាំងនោះ មានដូចជា៖

- ការពឹងផ្អែកលើជំនួយអន្តជាតិ : ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុពឹងផ្អែកខ្លាំងលើ WB, IMF, ADB និង IFC ដែលអាចបង្កហានិភ័យប្រសិនបើមានការបន្ថយជំនួយ ការជម្រុញទិសដៅឌីជីថលមកពីអន្តរជាតិអាចមិនសមនឹងស្ថានភាពក្នុងស្រុកទាំងអស់។
- ចំណេះដឹងទាក់ទងនឹងហិរញ្ញវត្ថុនៅមានកម្រិត (Financial Literacy)

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ៥.១ សេចក្តីសន្និដ្ឋាន

បន្ទាប់ពីក្រុមយើងខ្ញុំបានសិក្សាស្រាវជ្រាវ និងប្រមូលឯកសារមួយរយៈកន្លងមកលើប្រធានបទស្តីពីការរីកចម្រើននៃវិស័យហិរញ្ញវត្ថុនៅកម្ពុជានៅក្នុងអំឡុងឆ្នាំ២០២៤ ក្រុមយើងខ្ញុំអាចធ្វើការវិភាគ និងសន្និដ្ឋានបានថាវិស័យហិរញ្ញវត្ថុ នៅកម្ពុជាពិតជាមានការរីកចម្រើនពិតមែន ក្នុងការជំរុញសេដ្ឋកិច្ចជាតិឱ្យមានស្ថិរភាព ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជាបានឆ្ពោះទៅមុខយ៉ាងខ្លាំងបង្ហាញពីកម្រិតនៃការចូលរួមរបស់ប្រជាជនកាន់តែខ្ពស់ ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលកាន់តែទូលំទូលាយ និងការអភិវឌ្ឍគោលនយោបាយច្បាស់លាស់ ដើម្បីរក្សាស្ថិរភាពសេដ្ឋកិច្ច និងលើកស្ទួយភាពរឹងមាំនៃប្រព័ន្ធហិរញ្ញវត្ថុជាតិ។ រដ្ឋាភិបាលកម្ពុជា និង NBC បានអនុវត្តយុទ្ធសាស្ត្រសំខាន់ៗ ដូចជាការផ្តត់ផ្គង់ធនធានហិរញ្ញវត្ថុទៅសហគ្រិនខ្នាតតូច និងមធ្យម (SMEs) ការផ្សព្វផ្សាយការយល់ដឹងហិរញ្ញវត្ថុ និងការបង្កើតបរិយាកាសប្រកួតប្រជែងសម្រាប់ FinTech និងការទូទាត់ឌីជីថល។ យ៉ាងណាមិញ វិស័យនេះក៏នៅប្រឈមមុខនឹងបញ្ហា និងឧបសគ្គមួយចំនួនដូចជាការពឹងផ្អែកលើជំនួយអន្តជាតិ និងចំណេះដឹងទាក់ទងនឹងហិរញ្ញវត្ថុនៅមានកម្រិត (Financial Literacy)។ សរុបមក ការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុនៅកម្ពុជា បានបង្ហាញពីនិរន្តភាពនៃការលើកកម្ពស់សេដ្ឋកិច្ចជាតិតាមបែបឌីជីថល ទាំងនេះជួយធ្វើឱ្យប្រជាជនកាន់តែចូលរួមនៅក្នុងប្រព័ន្ធហិរញ្ញវត្ថុផ្លូវការណាស់ ហើយក៏បង្កើតលក្ខណៈសមរម្យសម្រាប់ការទាក់ទាញវិនិយោគក្នុងស្រុកនិងអន្តរជាតិផងដែរ។ ការអភិវឌ្ឍជាបន្តបន្ទាប់ដោយផ្តោតលើសុវត្ថិភាព ប្រសិទ្ធភាព និងភាពស្មើភាព នឹងជាចាំបាច់ដើម្បីធានាបាននូវវិស័យហិរញ្ញវត្ថុដែលរឹងមាំ និងទាន់សម័យជាមួយនឹងអនាគតសេដ្ឋកិច្ចឌីជីថល។

ជាចុងបញ្ចប់ ក្រុមយើងខ្ញុំសូមធ្វើការអភ័យទោសនិងអធ្យាស្រ័យអំពីសំណាក់ សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ មិត្តអ្នកអាន និងអ្នកស្រាវជ្រាវទាំងអស់ចំពោះកំហុសខុសឆ្គងក្នុងប្រការណាមួយដែលបានកើតឡើងដោយអចេតនាពីព្រោះវាគ្រាន់តែការលើកយកមកបង្ហាញអំពីកិច្ចការស្រាវជ្រាវដែលទាក់ទងអំពីប្រធានបទ «ការរីកនៃចម្រើនវិស័យហិរញ្ញវត្ថុនៅកម្ពុជា» បន្ថែមលើមេរៀនដែលបានសិក្សាកន្លងមកតែប៉ុណ្ណោះ។ ថ្វីត្បិតកិច្ចការស្រាវជ្រាវនេះ មិនបង្ហាញពីទិន្នន័យគ្រប់ជ្រុងជ្រោយទាំងអស់ក៏ពិតមែន ប៉ុន្តែឯកសារនេះ អាចទុកជាប្រយោជន៍សម្រាប់និស្សិតជំនាន់ក្រោយជាគំរូក្នុងការស្វែងយល់ និងស្រាវជ្រាវដែលទាក់ទងជុំវិញ ប្រធានបទការរីកចម្រើនវិស័យហិរញ្ញវត្ថុនៅកម្ពុជាផងដែរ។ ក្រុមយើងខ្ញុំ សូមទទួលការចូលរួមចំណែកក្នុងការកែលម្អដើម្បីស្ថាបនាដោយការយោគយល់ និងអនុគ្រោះដោយក្តីរីករាយ។

## ៥.២ ការផ្តល់អនុសាសន៍

ឆ្លងតាមការសន្និដ្ឋានលើការស្រាវជ្រាវទាក់ទងនឹងប្រធានបទខាងលើនេះរួចមក ក្រុមយើងខ្ញុំសង្កេតឃើញថាមានចំណុចខ្លាំងជាច្រើន ដែលជាឧបករណ៍ជម្រុញសំខាន់សម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចដូចដែលបានរៀបរាប់ខាងលើក្តី តែយ៉ាងណាវិញក៏នៅមានចំណុចខ្វះខាតមួយចំនួនតូច ដែលគួរតែធ្វើការកែលម្អឱ្យបានកាន់តែប្រសើរឡើងចំពោះវិស័យហិរញ្ញវត្ថុមានដូចខាងក្រោម៖

- ការពឹងផ្អែកលើជំនួយអន្តរជាតិ : បន្ថែមសមត្ថភាពក្នុងស្រុក ដោយកាត់បន្ថយការពឹងផ្អែកលើជំនួយអន្តរជាតិ និងអភិវឌ្ឍឌីជីថលស្របនឹងបរិបទជាតិ។
- ចំណេះដឹងទាក់ទងនឹងហិរញ្ញវត្ថុនៅមានកម្រិត (Financial Literacy) : បង្កើន Financial Literacyតាមរយៈកម្មវិធីអប់រំជាផ្លូវការនិងឧបករណ៍ឌីជីថលដើម្បីពង្រឹងសមត្ថភាពគ្រប់គ្រងហិរញ្ញវត្ថុរបស់ប្រជាពលរដ្ឋ។

# ឯកសារយោង


១.ក្រុមការងារហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម. (ខែមេសារ ឆ្នាំ២០២៤). *«ធានាចីរភាពហិរញ្ញវត្ថុសាធារណៈ ដើម្បីពង្រឹងភាពធន និងជំរុញកំណើនសេដ្ឋកិច្ច»* ៤១ទំព័រ

២.NBC. (2025, April 02). *"History of National Bank"* Retrieved form https://www.nbc.org.kh (Accessed March, 3 2025)

៣.Economy and Commerce. (2025, May 05). *"Bank Sector"* Retrieved form https://opendevelopmentcambodia.net (Accessed March, 3 2025)

៤.Cambodia Investment Review. (2024, April,18). "Bank Sector" Retrieved form https://cambodiainvestmentreview.com (Accessed March, 3 2025)

៥.SERC. (2025, May 07). *"Securities Sector"* Retrieved form https://www.serc.gov.kh/english (Accessed March, 08 2025)

៦.IFR (2023, November 17) *"Securities Sector"* Retrieved form https://www.ifre.com/esg/2074826 (Accessed March, 08 2025)

៧.Roxanne Libatique. (2025, February,17). *"Insurance Sector*" Retrieved form Cambodia's insurance industry grows as claims see sharp rise | Insurance Business Asia (Accessed March, 03 2025)

៨.AAR. (2024, December 16). *"Insurance Sector"* Retrieved form https://acar.gov.kh/news/detail/2847 (Accessed March, 08 2025)

៩.IMF. (2025, January 27). *"Financial and Economic Stability"* Retrieved form https://www.imf.org/en/News/Articles (Accessed March, 08 2025)

១០.FSB. (2024). *"Annual Report"* Retrieved form https://www.fsb.org/uploads/P181124-2.pdf (Accessed March, 3 2025)

១១.Rodolfo Maino. (2024, February 27). *"Development of the banking and credit institutions sector"* Retrieved form https://www.elibrary.imf.org/display/book/9781475560787/ch009.xml (Accessed March, 15 2025)

១២.PGS. (2025, May 16). *"CGCC"* Retrieved form https://www.cgcc.com.kh/en/portfolio-guarantee-scheme/ (Accessed March, 16 2025)

១៣.Prepare by Digital Economy and Business Committee. (2023, July). "*Cambodia Financial Technology development policy"* 2023-2028 Retrieved form https://www.khmersme.gov.kh/ (Accessed March, 30 2025)

១៤.IFC. (2024, October 17). *"Green loan Program"* Retrieved form https://www.ifc.org/en/pressroom/2024/ifc-and-association-of-banks-in-cambodia-to-boost-green-finance-support-sustainable-growth (Accessed March, 30 2025)

# ឧបសម្ព័ន្ធ






ធនាគារជាតិនៃកម្ពុជា
NATIONAL BANK OF CAMBODIA
Development.
ASIA
Bank Logo
SOSORO MUSEUM
Shinhan
LOLC
SBI LH
PPCBank
true money
FTB
KB


BANKING
DATA
downloading 70% c
35%
25%
25%
10%
5%
89%



គម្រោងសាងសង់អគារស្នាក់ការធនាគារជាតិនៃកម្ពុជា ស្ថិតនៅទីតាំងបច្ចុប្បន្ន